ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# យុទ្ធសាស្ត្រ
# ស្តីពី
# ការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច
# ឆ្នាំ ២០២៥-២០២៨



ឆ្នាំ ២០២៥

“ចូលរួមបង្កើតបរិយាកាសអំណោយផលសម្រាប់ការធ្វើធុរកិច្ច
តាមរយៈការផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ដែលមានប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព
និង តម្លាភាព ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង”

**ឆ្នាំ ២០២៥**




“ គ្រប់ក្រសួង ស្ថាប័នត្រូវពិនិត្យសេវាសាធារណៈសម្រាប់ធុរកិច្ចរបស់ខ្លួនឡើងវិញ ដើម្បីកែសម្រួលនីតិវិធីនៃការផ្តល់សេវា និងដើម្បីពិនិត្យលទ្ធភាពផ្តួបបញ្ចូលគ្នានូវលិខិតអនុញ្ញាត អាជ្ញាបណ្ណ និងវិញ្ញាបនបត្រដែលមានតម្លៃប្រហាក់ប្រហែលគ្នា ឬមិនមានតម្លៃបន្ថែមខ្ពស់, និងត្រូវបន្តខិតខំរៀបចំដាក់បញ្ចូលសេវាទាំងនេះទៅក្នុងយន្តការចុះបញ្ជីអាជីវកម្មតាមថ្នាល CamDX សំដៅបង្កើតបាន ប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច មួយ ដែលចូលរួមកែលម្អបរិយាកាសធុរកិច្ចក្នុងប្រទេស និងបង្កើនភាពទាក់ទាញរបស់កម្ពុជាសម្រាប់ការវិនិយោគ។ ”

# បុព្វកថា

ក្នុងរយៈពេលជាង ២ ទសវត្សរ៍ចុងក្រោយនេះ, បច្ចេកវិទ្យាឌីជីថលបាន និង កំពុងរីកចម្រើនយ៉ាងឆាប់រហ័ស និង បានក្លាយជាកាតាលីករសំខាន់សម្រាប់ជំរុញសកម្មភាពសេដ្ឋកិច្ចទូទាំងសកលលោក រួមទាំងកម្ពុជាផងដែរ ដែលបានកែប្រែរបៀបរបបនៃការរស់នៅ និង ការបំពេញការងារ ទាំងក្នុងវិស័យឯកជន និង វិស័យសាធារណៈ។ ក្នុងវិស័យឯកជន ការចាប់យកបច្ចេកវិទ្យាឌីជីថលមកប្រើប្រាស់ក្នុងប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ជាឧត្តមភាពមួយថ្មី ដែលអាចជួយលើកកម្ពស់និងរក្សាបានចីរភាពនៃការធ្វើអាជីវកម្ម ដូចដែលកម្ពុជាបានឆ្លងកាត់ក្នុងអំឡុងវិបត្តិជំងឺកូវីដ-១៩។ មិនត្រឹមតែប៉ុណ្ណោះ បច្ចេកវិទ្យាឌីជីថល ក៏បានជួយសម្រួលដល់ប្រតិបត្តិការអាជីវកម្ម កាត់បន្ថយថ្លៃដើម បង្កើនប្រសិទ្ធភាពការងារ និងជាពិសេស ជួយពង្រីកទីផ្សារនៃការលក់ផលិតផល ឬ សេវាកម្មទៅអតិថិជនបន្ថែម។ មិនខុសគ្នាពីវិស័យឯកជន, ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងវិស័យសាធារណៈ ត្រូវបានចាត់ទុកជាកាលានុវត្តភាពគន្លឹះ និងជាឧបករណ៍មិនអាចខ្វះបានក្នុងការជំរុញការងារកែទម្រង់ពាក់ព័ន្ធនានា សំដៅធានាបានប្រសិទ្ធភាពការងារខ្ពស់ ជាពិសេសការបង្ហិតសេវាសាធារណៈរបស់ខ្លួន ទៅកៀកនឹងប្រជាពលរដ្ឋទូទៅ និង វិស័យឯកជន។

ការធ្វើទំនើបកម្មការផ្តល់សេវាសាធារណៈនៅកម្ពុជា ជាពិសេសសេវាសម្រាប់ធុរកិច្ច ជាការងារអាទិភាពរបស់រាជរដ្ឋាភិបាល ទាំងក្នុងនីតិកាលទី ៦ នៃរដ្ឋសភា និង បច្ចុប្បន្ន។ ក្រោមការដឹកនាំប្រកបដោយភាពប្រាកដនិយម និង ទស្សនវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី** និងបច្ចុប្បន្នជា **ប្រធានព្រឹទ្ធសភា** ការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ចត្រូវបានកែលម្អ និង ធ្វើទំនើបកម្មជាបន្តបន្ទាប់។ ជាក់ស្តែង នៅឆ្នាំ ២០២០ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន តាមរយៈការចែករំលែកទិន្នន័យតាមថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) ក្នុងប្រព័ន្ធអេកូឡូស៊ីរួម ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធជាលើកដំបូង។ ការចុះបញ្ជីតាមប្រព័ន្ធអេកូឡូស៊ីរួមនេះ បានជួយសម្រួលនីតិវិធី កាត់បន្ថយភាពស្មុគស្មាញ ទាំងពេល និង ថវិការបស់ធុរជនក្នុងការស្នើសុំសេវាចុះបញ្ជីអាជីវកម្ម នៅតាមក្រសួងស្ថាប័នពាក់ព័ន្ធ ដែលជាការផ្លាស់ប្តូរថ្មីមួយ បង្កភាពងាយស្រួលដល់ការចាប់ផ្តើមអាជីវកម្មនៅកម្ពុជា។ ដោយត្រូវបានអនុវត្តជាដំណាក់កាល, ប្រព័ន្ធចុះបញ្ជីអាជីវកម្មនេះ បានពង្រីកវិសាលភាពទៅដល់ការស្នើសុំអាជ្ញាបណ្ណជំនាញតាមវិស័យទៀតផង ដែលជួយសម្រួលការបំពេញអនុលោមភាពរបស់ធុរកិច្ចសម្រាប់ដំណើរការអាជីវកម្មពេញលេញរបស់ខ្លួន។ ទោះបីជានៅជួបប្រទះបញ្ហាប្រឈមមួយចំនួន, យើងអាចនិយាយថា ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលមានអន្តរប្រតិបត្តិការរវាងគ្នាក្នុងប្រព័ន្ធអេកូឡូស៊ីរួម ជាដំណោះស្រាយមួយសមស្របសម្រាប់កម្ពុជា ដែលអាចជួយបង្កើនប្រសិទ្ធភាពការងាររវាងក្រសួង ស្ថាប័ន និង កាត់បន្ថយភាពស្មុគស្មាញ។

សម្រាប់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា, យើងមានបេសកកម្មបន្តពង្រឹង និង ពង្រីកការអនុវត្តការងារទំនើបកម្មការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ចនេះ ក្នុងប្រព័ន្ធអេកូឡូស៊ីរួម ស្របតាមអភិក្រម "**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**" ។ ដូចមាននៅក្នុង «**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**»,

រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ខ្ពស់លើការពង្រឹងសមត្ថភាពស្ថាប័ន និង អភិបាលកិច្ច ដើម្បីសម្រេចបាននូវរដ្ឋបាលសាធារណៈទំនើប ដែលមាន **សមត្ថភាពខ្ពស់, ខ្លាំង, វៃឆ្លាត និង ស្អាតស្អំ** តាមរយៈការធ្វើទំនើបកម្ម ឬ ឌីជីថលូបនីយកម្មការផ្តល់សេវាសាធារណៈ ជាពិសេសសេវាសាធារណៈសម្រាប់ធុរកិច្ច ដើម្បីលើកកម្ពស់បរិយាកាសធ្វើធុរកិច្ចនៅកម្ពុជា។ ជាមួយគ្នានេះ, ក្នុង**វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី ១៩** នាថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០២៣ កន្លងទៅ រាជរដ្ឋាភិបាល ក៏បានណែនាំឱ្យក្រសួង ស្ថាប័ន ពិនិត្យឡើងវិញនូវលិខិតអនុញ្ញាត និង អាជ្ញាបណ្ណទាំងអស់ ក្នុងវិស័យនីមួយៗ ដើម្បីលុបចេញ ឬ ផ្តួបចូលគ្នានូវលិខិតអនុញ្ញាត និង អាជ្ញាបណ្ណ ដែលត្រួតស៊ីគ្នា ព្រមទាំងកែសម្រួលនីតិវិធីស្នើសុំ និង កម្រៃសេវា ក្នុងគោលដៅធានាឱ្យបានថាគ្មាននីតិវិធីមួយណា អាចបង្កការលំបាក និង ភាព-មិនចាំបាច់ដល់អ្នកស្នើសុំសេវា។

ឈរលើបទពិសោធជោគជ័យកន្លងមក និង បញ្ហាប្រឈមចំពោះមុខ, ការរៀបចំ «**យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨**» ពិតជាមានភាពចាំបាច់ ជាមួយនឹងការដាក់ចេញនូវវិធានការមុតស្រួចប្រកបដោយភាពប្រាកដនិយម និងភាពគ្រប់ជ្រុងជ្រោយ ក្នុងការឈានទៅបង្កើត **"ប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច"** មួយដ៏រឹងមាំ, បំពេញគ្នាទៅវិញទៅមក និង រស់រវើក ដែលគាំទ្រដល់ការបង្កើតបរិយាកាសអំណោយផលសម្រាប់ការ-ធ្វើធុរកិច្ច តាមរយៈការផ្តល់សេវាអេឡិចត្រូនិក ដើម្បីចូលរួមចំណែកដល់ការសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០។ យុទ្ធសាស្ត្រនេះ ជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដែលមានតួអង្គសម្របសម្រួល និង ជំរុញការអនុវត្តសំខាន់ៗ ដូចជា គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល, គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ, គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល, ក្រុមការងារអន្តរក្រសួងរៀបចំសេវា-អេឡិចត្រូនិកសម្រាប់ធុរកិច្ច និង ក្រសួងស្ថាប័នពាក់ព័ន្ធ។ ភាពជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រនេះទាមទារការចូលរួម និង ការផ្តល់កិច្ចសហការយ៉ាងជិតស្និទ្ធពីក្រសួង ស្ថាប័នអនុវត្តការងារផ្ទាល់ផងដែរ។

ខ្ញុំជឿជាក់យ៉ាងមុតមាំថា យុទ្ធសាស្ត្រនេះ នឹងក្លាយជាឯកសារបង្ហាញផ្លូវមួយដ៏សំខាន់ សម្រាប់ក្រសួង ស្ថាប័ន ក្នុងការទាញយកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មឌីជីថល ដើម្បីរៀបចំផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចនៅកម្ពុជា។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា, ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល** សម្រាប់ការដឹកនាំ និង តម្រង់ទិសការរៀបចំយុទ្ធសាស្ត្រដ៏មានសារៈសំខាន់នេះឡើង។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ **ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈ-កម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ** និង **ឯកឧត្តម ជា វ៉ាន់ដេត រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងជាប្រធានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល** ដែលបានផ្តល់ការគាំទ្រ និង ការប្តេជ្ញាចូលរួមជំរុញការអនុវត្តយុទ្ធសាស្ត្រនេះផងដែរ។ ទន្ទឹមនេះ, ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី ប្រធានក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច** និង សមាជិកនៃក្រុម-ការងារទាំងអស់ ដែលបានខិតខំប្រឹងប្រែងរៀបចំយុទ្ធសាស្ត្រនេះ រហូតសម្រេចបានជាស្ថាពរ។ ខ្ញុំសូម

លើកទឹកចិត្តឱ្យគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់អនុវត្តយុទ្ធសាស្ត្រនេះ ប្រកបដោយភាពបុរេសកម្ម និង ការទទួលខុសត្រូវខ្ពស់ ក្រោមស្មារតីនៃការកែទម្រង់ជាមួយនឹងអភិក្រម "**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**" និង អភិក្រមការងារទាំង ៥ គឺ "**ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល និង វះកាត់**" ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច និង អាចបង្កើតបរិយាកាសអំណោយផលឱ្យប្រសើរបន្ថែមទៀតសម្រាប់ការធ្វើធុរកិច្ចនៅកម្ពុជា។

ថ្ងៃពុធ ១៥កើត ខែមាឃ ឆ្នាំ រោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ:** ៣៧៧ សជណ.ហជ

ថ្ងៃព្រហស្បតិ៍ ៨កើតខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែមីនា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សូមជម្រាបជូន**

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**កម្មវត្ថុ** ៖ ករណីការស្នើសុំពិនិត្យនិងសម្រេចអនុម័តដ៏ខ្ពង់ខ្ពស់លើសេចក្តីព្រាង "យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចឆ្នាំ ២០២៥-២០២៨"។

**យោង** ៖- លិខិតលេខ៨២៤ សហវ.ល.ស ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- លិខិតលេខ២០៥២ សហវ.ល.ស ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ មេត្តាជ្រាបថា រាជរដ្ឋាភិបាលសម្រេចអនុម័តក្នុងការដាក់ឱ្យអនុវត្ត "យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចឆ្នាំ ២០២៥-២០២៨"។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ មេត្តាជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

**ចម្លងជូន៖**

-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ

-គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល

-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ

-ឯកសារ កាលប្បវត្តិ

# មាតិកា

**បុព្វកថា** .................... i
**បញ្ជីពាក្យកាត់** .................... vi
**បញ្ជីរូបភាព** .................... vii
**ខ្លឹមសារសង្ខេប** .................... viii
**១- សេចក្តីផ្តើម** .................... ១
**២- សនិទានកម្មនៃការរៀបចំយុទ្ធសាស្ត្រ** .................... ៣
២.១- ស្ថានភាពនៃការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ចនៅកម្ពុជា .................... ៣
២.២- បញ្ហាប្រឈម .................... ៥
២.៣- បទពិសោធជាអន្តរជាតិ .................... ៧
**៣- ក្របខ័ណ្ឌរួមនៃយុទ្ធសាស្ត្រ** .................... ៩
៣.១- ចក្ខុវិស័យ គោលបំណង និង គោលដៅ .................... ៩
៣.២- និយមន័យ និង វិសាលភាព .................... ៩
៣.៣- ប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច .................... ១០
៣.៣.១- តួអង្គសំខាន់ និង អន្តរសេកម្ម .................... ១០
៣.៣.២- គោលការណ៍នៃការកសាងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច .................... ១២
៣.៤- អាទិភាពជាយុទ្ធសាស្ត្រ .................... ១៣
៣.៤.១- ការពិនិត្យឡើងវិញ និង កែសម្រួលសេវានិងនីតិវិធីស្នើសុំ .................... ១៤
៣.៤.២- ការអភិវឌ្ឍ និង បន្តធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច .................... ១៤
៣.៤.៣- ការរៀបចំ និង ធ្វើទំនើបកម្មទិន្នន័យគោលឱ្យមានគុណភាព ក្នុងក្របខ័ណ្ឌធុរកិច្ច .................... ១៥
៣.៤.៤- ការជំរុញការផ្សព្វផ្សាយព័ត៌មានអំពីសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច .................... ១៦
៣.៤.៥- ការលើកកម្ពស់សមត្ថភាពមន្ត្រីផ្តល់សេវា និង ការរៀបចំយន្តការគាំទ្រអ្នកប្រើប្រាស់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច .................... ១៦
**៤- យន្តការចាត់ចែងអនុវត្ត, តាមដាន និង វាយតម្លៃ** .................... ១៨
៤.១- យន្តការចាត់ចែងអនុវត្ត .................... ១៨
៤.២- យន្តការតាមដាន និង វាយតម្លៃ .................... ១៩
**៥- ការគ្រប់គ្រងហានិភ័យ** .................... ២១
**៦- សេចក្តីសន្និដ្ឋាន** .................... ២២
**ឧបសម្ព័ន្ធ ១- តារាងវិធានការគន្លឹះនៃយុទ្ធសាស្ត្រ** .................... ២៣
**ឧបសម្ព័ន្ធ ២- សទ្ទានុក្រម** .................... ២៧
**ឧបសម្ព័ន្ធ ៣- គោលការណ៍ណែនាំផ្នែកបច្ចេកទេស** .................... ៣០

# បញ្ជីពាក្យកាត់

| | |
|---|---|
| CamDigiKey | ថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា (Cambodia Digital Key) |
| CamDX | ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cambodia Data Exchange ) |
| DPI | ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល (Digital Public Infrastructure) |
| OBR | ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (Online Business Registration) |
| API | សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (អេភីអាយ) (Application Programming Interface) |
| OWASP | គម្រោងសុវត្ថិភាពកម្មវិធីវេប (Open Web Application Security Project) |
| BPR | ការកែសម្រួលនីតិវិធីការងារ (Business Process Re-engineering) |

# បញ្ជីរូបភាព


រូបភាពទី១: ប្រព័ន្ធអេកូឡូស៊ីនៃការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ........................ ៤

រូបភាពទី២: អន្តរសេកម្មក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច ...................................... ១១

រូបភាពទី៣: គោលការណ៍នៃការរៀបចំប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច .......................... ១៣

រូបភាពទី៤: ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល ............................................................ ១៥

រូបភាពទី៥: ទិន្នន័យគោលក្នុងក្របខ័ណ្ឌធុរកិច្ច.................................................................. ១៦

រូបភាពទី៦: ក្របខ័ណ្ឌរួមនៃយុទ្ធសាស្ត្រស្ដីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨ .................................................................................. ១៧

រូបភាពទី៧: យន្តការស្ថាប័ន................................................................................................. ២០

# ខ្លឹមសារសង្ខេប

ស្របតាមនិន្នាការនៃឧស្សាហកម្ម ៤.០ និង ទិសដៅគោលនយោបាយរបស់ខ្លួន, រាជរដ្ឋាភិបាលបាន និង កំពុងបង្វិតសេវាសាធារណៈរដ្ឋបាលនិងធុរកិច្ចទៅជិតប្រជាពលរដ្ឋនិងធុរជន និង ពង្រឹងគុណភាពនៃការផ្តល់សេវា តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដើម្បីកសាងបរិយាកាសធុរកិច្ច និង វិនិយោគនៅកម្ពុជាឱ្យកាន់តែមានភាពអំណោយផល សំដៅជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមប្រកបដោយបរិយាបន្ន។ ជាក់ស្តែង, សេវាសាធារណៈគាំទ្រដល់ធុរកិច្ចមួយចំនួន ត្រូវបានរៀបចំ និង ដាក់ឱ្យអនុវត្តតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងស្រុងរួចរាល់ហើយ រួមមាន សេវាពាក់ព័ន្ធនឹងការចុះបញ្ជីអាជីវកម្មជាកញ្ចប់នៃខ្សែប្រវាក់ និង ការស្នើសុំអាជ្ញាបណ្ណ វិញ្ញាបនបត្រ និង លិខិតអនុញ្ញាតតាមវិស័យមួយចំនួនជាដើម។ ទន្ទឹមនេះ, ការផ្តល់សេវាសម្រាប់ធុរកិច្ចផ្សេងទៀត ក៏នៅមានបញ្ហាប្រឈមជាអាទិ៍ នីតិវិធីក្នុងការស្នើសុំសេវាមានភាពស្មុគស្មាញ, ការផ្តល់សេវាមួយចំនួនធ្វើឡើងតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ប៉ុន្តែនៅដាច់ដោយឡែកពីគ្នា និង ពុំអាចធ្វើអន្តរប្រតិបត្តិការបាន, នៅខ្វះខាតស្តង់ដាររួម និង គោលការណ៍ណែនាំបច្ចេកទេសសម្រាប់ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង ការតភ្ជាប់រវាងប្រព័ន្ធ និង ប្រព័ន្ធ ហើយការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល និង ហេដ្ឋារចនាសម្ព័ន្ធឌីជីថលគាំទ្ររួមតាមក្រសួង ស្ថាប័ននៅមានកម្រិត រួមផ្សំនឹងការផ្តល់ព័ត៌មានពាក់ព័ន្ធនៅពុំទាន់ទូលំទូលាយ។

ក្នុងបរិការណ៍នេះ, «**យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨**» ត្រូវបានរៀបចំឡើងដោយដាក់ចេញនូវចក្ខុវិស័យ "**ចូលរួមបង្កើតបរិយាកាសអំណោយផលសម្រាប់ការធ្វើធុរកិច្ច តាមរយៈការផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ដែលមានប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព និង តម្លាភាព ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង**" និង មានគោលបំណង "**បង្កើតប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច ប្រកបដោយភាពរស់រវើក, ភាពធន់, ប្រទាក់ក្រឡា និង បំពេញឱ្យគ្នាទៅវិញទៅមក សំដៅពង្រឹងប្រសិទ្ធភាពនៃយន្តការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច និង លើកកម្ពស់ការបំពេញអនុលោមភាព**"។ ការកសាងប្រព័ន្ធអេកូឡូស៊ីឌីជីថលនេះ ត្រូវឈរលើគោលការណ៍គ្រឹះទាំង ៣ ដែលបានកំណត់ក្នុង «**ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥**» និង «**គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥**» គឺ គោលការណ៍បញ្ចូលទិន្នន័យតែមួយលើក, គោលការណ៍អន្តរប្រតិបត្តិការជាប្រព័ន្ធអេកូឡូស៊ីតែមួយ, និង គោលការណ៍ផ្តួចផ្តើម និង ពង្រីកដើម្បីប្រសិទ្ធផល, ព្រមទាំងគោលការណ៍ជាក់លាក់ចំនួន ២ បន្ថែមទៀត ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ គឺ គោលការណ៍គាំទ្រធុរកិច្ចជាចម្បង និង គោលការណ៍ឧត្តមភាពនៃប្រតិបត្តិការ។

ដើម្បីសម្រេចបាននូវចក្ខុវិស័យ និង គោលបំណងខាងលើ, យុទ្ធសាស្ត្រនេះបានកំណត់គោលដៅសំខាន់ចំនួន ៤ គឺ៖ ១). កែសម្រួល ឬ លុបចេញសេវា និង នីតិវិធីការងារក្នុងការស្នើសុំសេវាដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ឬមិនមានតម្លៃបន្ថែមខ្ពស់ ដើម្បីបង្រួម និង ធានាភាពងាយស្រួលក្នុងការស្នើសុំសេវាសម្រាប់ធុរកិច្ចដល់ធុរជន, ២). កសាង និង អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្តល់

សេវាអេឡិចត្រូនិក ឱ្យដំណើរការនៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច ផ្អែកលើគោលការណ៍ប្រសិទ្ធភាពនៃការវិនិយោគ, ៣). ធ្វើអាទិភាវូបនីយកម្មសេវាសម្រាប់ធុរកិច្ចផ្អែកលើភាពចាំបាច់ និងតម្រូវការខ្ពស់ និង ដាក់ឱ្យដំណើរការសេវាចំនួន ៨០% នៃសេវាអាទិភាពទាំងនោះតាមប្រព័ន្ធបច្ចេកវិទ្យា-ព័ត៌មានត្រឹមឆ្នាំ ២០២៨, និង ៤). ផ្សព្វផ្សាយព័ត៌មាន និង បញ្ជ្រាបការយល់ដឹងអំពីសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ដើម្បីលើកកម្ពស់ការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធ។ បន្ថែមលើនេះ, យុទ្ធសាស្ត្រនេះបានដាក់ចេញនូវអាទិភាពជាយុទ្ធសាស្ត្រចំនួន ៥ រួមមាន៖ ១). ការពិនិត្យឡើងវិញ និង កែសម្រួលសេវានិងនីតិវិធីស្នើសុំ, ២). ការអភិវឌ្ឍ និង ការបន្តធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ប្រព័ន្ធបច្ចេកវិទ្យា-ព័ត៌មានសម្រាប់ផ្តល់សេវាអេឡិចត្រូនិកគាំទ្រធុរកិច្ច, ៣). ការរៀបចំ និង ការធ្វើទំនើបកម្មទិន្នន័យគោលឱ្យមានគុណភាពក្នុងក្របខ័ណ្ឌធុរកិច្ច, ៤). ការជំរុញការផ្សព្វផ្សាយព័ត៌មានអំពីសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច និង ៥). ការលើកកម្ពស់សមត្ថភាពមន្ត្រីផ្តល់សេវា និង ការរៀបចំយន្តការគាំទ្រអ្នកប្រើ-ប្រាស់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច។ អាទិភាពជាយុទ្ធសាស្ត្រទាំង ៥ នេះ មានវិធានការគន្លឹះសរុបចំនួន ២១។

ការរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច មានវិសាលភាពគ្របដណ្តប់លើគ្រប់សេវាបម្រើដល់វិស័យធុរកិច្ចតាមវដ្តនៃការធ្វើធុរកិច្ច រួមមាន ការចុះបញ្ជី, ការស្នើសុំអាជ្ញាបណ្ណជំនាញ, លិខិតអនុញ្ញាត, វិញ្ញាបនបត្រ ឬ សេវាផ្សេងៗពាក់ព័ន្ធនឹងការចាប់ផ្តើមអាជីវកម្ម ការប្រតិបត្តិអាជីវកម្ម និង ការផ្អាក ឬ បិទអាជីវកម្ម របស់សហគ្រាសគ្រប់ប្រភេទ ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ។ ភាពជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រនេះ អាស្រ័យលើកិច្ចសហការយ៉ាងជិតស្និទ្ធ ប្រកបដោយឆន្ទៈ និង ស្មារតីទទួល-ខុសត្រូវខ្ពស់របស់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេស **ក្រសួង ស្ថាប័នផ្តល់ ឬ ម្ចាស់សេវាសម្រាប់ធុរកិច្ច** ក្រោមកិច្ចសម្របសម្រួលផ្ទាល់របស់**លេខាធិការដ្ឋាននៃក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច**។ បន្ថែមលើនេះ, **គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ** និង **គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល** នឹងដើរតួនាទីចូលរួមសម្របសម្រួលគាំទ្រទាំងផ្នែកបច្ចេកទេស និង នីតិវិធី ខណៈដែល **គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល** មានតួនាទីត្រួតពិនិត្យ តាមដាន និង វាយតម្លៃលើការអនុវត្តយុទ្ធសាស្ត្រជារួម។

ជារួម, **«យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨»** នឹងក្លាយជាផែនទីបង្ហាញផ្លូវមួយយ៉ាងសំខាន់សម្រាប់ក្រសួង ស្ថាប័ន ក្នុងការផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចប្រកបដោយស័ក្តិសិទ្ធភាព, ប្រសិទ្ធភាព, គណនេយ្យភាព និង តម្លាភាព។ ការអនុវត្តយុទ្ធសាស្ត្រនេះ នឹងពង្រឹងការផ្តល់សេវាធុរកិច្ចប្រកបដោយគុណភាពខ្ពស់, ការសម្រួលនីតិវិធី, ការ-កាត់បន្ថយពេលវេលា និង បន្ទុកចំណាយថវិការបស់ធុរជន។ យុទ្ធសាស្ត្រនេះក៏ឆ្លើយតបទៅនឹងស្នូលនៃ **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»** របស់រាជរដ្ឋាភិបាល ក្នុងការចូលរួមបង្កើតរដ្ឋបាល-សាធារណៈទំនើប ប្រកបដោយ **សមត្ថភាពខ្ពស់, ខ្លាំង, វៃឆ្លាត, និង ស្អាតស្អំ** តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ការពង្រឹងសមត្ថភាពមន្ត្រីឱ្យខ្លាំង និង ការផ្តល់សេវាសាធារណៈបានល្អ។ លើសពីនេះ,

យុទ្ធសាស្ត្រនេះ នឹងចូលរួមបង្កើតបរិយាកាសល្អនៃការធ្វើធុរកិច្ចនៅកម្ពុជា និង ចូលរួមចំណែកដល់ការសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០។

«**យុទ្ធសាស្ត្រស្ដីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨**» ត្រូវបានចាត់ទុកជា "**ឯកសាររស់**" ដែលអាចនឹងត្រូវបានកែសម្រួលជាយថាហេតុ ក្នុងករណីចាំបាច់ ដើម្បីធានាសង្គតិភាព និង ភាពសមស្របទៅតាមការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា ក៏ដូចជាការវិវឌ្ឍនៃស្ថានការណ៍សេដ្ឋកិច្ច និង សង្គម។

## ១- សេចក្តីផ្តើម

ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ, កម្ពុជាបានកសាងមូលដ្ឋានគ្រឹះសេដ្ឋកិច្ចមួយដ៏រឹងមាំ ដោយប្រកាន់យកប្រព័ន្ធសេដ្ឋកិច្ចទីផ្សារតាមរយៈ៖ ១). ការបើកចំហការធ្វើពាណិជ្ជកម្មអន្តរជាតិផ្អែកលើគោលការណ៍ពហុភាគីនិយម, ២). ការជំរុញ និង ទាក់ទាញបន្ថែមនូវការវិនិយោគផ្ទាល់ពីបរទេសតាមរយៈការកែសម្រួលបរិយាកាសធុរកិច្ច និង វិនិយោគ, ៣). ការពង្រឹង និង ការស្តារហេដ្ឋារចនាសម្ព័ន្ធរឹង ដូចជា ផ្លូវថ្នល់, ទឹក និង ភ្លើង ដើម្បីលើកកម្ពស់ការតភ្ជាប់ និង ភាពប្រកួតប្រជែង, ៤). ការបន្តអភិវឌ្ឍ និង ការលើកកម្ពស់មូលធនមនុស្ស ដើម្បីចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច និង បង្កើនផលិតភាព និង ៥). ការកែទម្រង់ស្ថាប័ន និង អភិបាលកិច្ចជាប្រចាំ ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធនយោបាយ និង សេដ្ឋកិច្ច។ ដោយផ្អែកលើមូលដ្ឋាននេះ កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងអត្រាជាមធ្យម ៨% ក្នុងមួយឆ្នាំ (ទិន្នន័យផលិតផលក្នុងស្រុកសរុបឆ្នាំគោលថ្មី ឆ្នាំ ២០១៤) នៅមុនវិបត្តិជំងឺកូវីដ-១៩ និង បានងើបចេញពីវិបត្តិនេះយ៉ាងឆាប់រហ័ស ក្នុងអត្រាកំណើនប្រមាណ ៥.១% នៅឆ្នាំ ២០២២ និង ៥.០% នៅឆ្នាំ ២០២៣ បើទោះបីវិបត្តិសកលផ្សេងទៀតកើតមានម្តងហើយម្តងទៀតក្តី។

ទន្ទឹមនេះ, នៅក្នុងបរិការណ៍នៃបដិវត្តន៍ឧស្សាហកម្មទី ៤, រាជរដ្ឋាភិបាលបាន និង កំពុងបង្កើនការអនុវត្តសកម្មភាព និង គម្រោងឌីជីថលនានា ដើម្បីជំរុញការចាប់យក និង ទាញប្រយោជន៍ជាអតិបរមាពីបច្ចេកវិទ្យាឌីជីថលស្របតាម "**ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥**" សំដៅកសាងសេដ្ឋកិច្ចនិងសង្គមឌីជីថលរស់រវើក និង "**គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥**" សំដៅកសាង និង អភិវឌ្ឍរដ្ឋាភិបាលឱ្យប្រែក្លាយជារដ្ឋាភិបាលឌីជីថល។ ជាមួយគ្នានេះ, «**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**» របស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា បានកំណត់យកការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលជាបញ្ចកោណទី ៥ ដែលក្នុងនោះមានមុំទី ២ ផ្តោតលើការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល, ធុរកិច្ចឌីជីថល, ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង ប្រព័ន្ធនវានុវត្តន៍ឌីជីថលផងដែរ។

ស្របតាមទិសដៅគោលនយោបាយនេះ, រាជរដ្ឋាភិបាលបាន និង កំពុងយកចិត្តទុកដាក់ខ្លាំងលើការធ្វើឌីជីថលូបនីយកម្មសេវាសាធារណៈសម្រាប់ធុរកិច្ច តួយ៉ាងការរៀបចំ និង ដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (Online Business Registration-OBR) សម្រាប់ការស្នើសុំចុះបញ្ជីអាជីវកម្មជាកញ្ចប់ និង ការស្នើសុំអាជ្ញាបណ្ណតាមវិស័យជាដើម។ បន្ថែមលើនេះ, នៅក្នុង **វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩** កាលពីថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០២៣ កន្លងទៅ, រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញវិធានការគន្លឹះដើម្បីបន្តជំរុញការចុះបញ្ជីអាជីវកម្មតាមថ្នាល OBR តាមរយៈការបញ្ចូលសេវាសាធារណៈគាំទ្រធុរកិច្ចរបស់ក្រសួង ស្ថាប័នបន្ថែម ដែលមានតម្រូវការញឹកញាប់អមជាមួយនឹងការពិនិត្យឡើងវិញនូវលិខិតអនុញ្ញាត និងអាជ្ញាបណ្ណទាំងអស់ក្នុងវិស័យនីមួយៗ ដែលអាចលុបចេញ ឬ ផ្តុំបញ្ចូលគ្នា នូវលិខិតអនុញ្ញាត និងអាជ្ញាបណ្ណដែលត្រួតស៊ីគ្នា ព្រមទាំងកែសម្រួលនីតិវិធី និង កម្រៃសេវា នៃលិខិតអនុញ្ញាត និង អាជ្ញាបណ្ណនីមួយៗ ឱ្យបានច្បាស់លាស់។

ក្នុងបរិការណ៍នេះ, ការរៀបចំយុទ្ធសាស្ត្ររួមសម្រាប់អភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច មានភាពចាំបាច់ និង សារៈសំខាន់ខ្ពស់ ក្នុងការពង្រីកការដ្ឋានការងារមានស្រាប់ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមដែលកំពុងជួបប្រទះ និង បំពេញបន្ថែមលើវិធានការគោលនយោបាយដែលអនុវត្តកន្លងមកសំដៅកាត់បន្ថយការបំពេញព័ត៌មានច្រើន និង នីតិវិធីស្មុគស្មាញ។ បន្ថែមលើនេះ, ការអភិវឌ្ឍ និង ការ-គ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ត្រូវធ្វើឡើងនៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ចតែមួយ ស្របតាមគោលការណ៍ និង ស្តង់ដាបច្ចេកទេសច្បាស់លាស់សំដៅធានាប្រសិទ្ធភាពនៃការវិនិយោគ។ យុទ្ធសាស្ត្រនេះ ជាផ្នែកមួយនៃការកែទម្រង់ការផ្តល់សេវាសាធារណៈតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយផ្តោតលើសេវាគាំទ្រដល់ធុរកិច្ច ព្រមទាំងរួមចំណែកដល់ការកែសម្រួលបរិយាកាសធុរកិច្ច និង វិនិយោគនៅកម្ពុជាឱ្យកាន់តែអំណោយផល និង មានភាព-រស់រវើកបន្ថែមទៀត សំដៅបង្កើនភាពប្រកួតប្រជែង, ជំរុញផលិតភាពសេដ្ឋកិច្ច និង ពង្រឹងភាពធន់ឆ្លើយតបនឹងវិបត្តិជាយថាហេតុផ្សេងៗ នាពេលអនាគត។

# ២- សនិទានកម្មនៃការរៀបចំយុទ្ធសាស្ត្រ

## ២.១- ស្ថានភាពនៃការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ចនៅកម្ពុជា

យោងតាមទិន្នន័យអង្កេតរបស់លេខាធិការដ្ឋានក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច, សេវាពាក់ព័ន្ធធុរកិច្ចផ្តល់ដោយក្រសួង ស្ថាប័ន មានសរុបចំនួន ៧១៤[១] ដែលសេវាទាំងនេះ ត្រូវបានផ្តល់ជូនអ្នកស្នើសុំតាមរយៈមធ្យោបាយផ្សេងៗ។ ជាក់ស្តែង, សេវាសម្រាប់ធុរកិច្ចចំនួន ៤៣២[២] ត្រូវបាន និង កំពុងអនុវត្តយន្តការទទួលពាក្យស្នើសុំដោយក្រដាសនៅឡើយ ព្រមទាំងការកត់ត្រាដោយដៃ ឬ វាយបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រតាមក្រោយ។ សេវាមួយចំនួនទៀត ត្រូវបានប្រើប្រាស់យន្តការទទួលពាក្យតាមរយៈប្រព័ន្ធតេឡេក្រាម ឬ អ៊ីម៉ែល ដោយរក្សាទុកក្រោមទម្រង់ឯកសារឌីជីថល (Portable Document Format-PDF)។

ទន្ទឹមនេះ, ការផ្តល់សេវាបែបពាក់កណ្តាលអនឡាញ សំដៅដល់ការប្រើប្រាស់ប្រព័ន្ធ ដែលអនុញ្ញាតឱ្យអ្នកស្នើសុំសេវា បំពេញពាក្យស្នើសុំតាមអនឡាញ ហើយនីតិវិធីសេសសល់ដទៃទៀតត្រូវអនុវត្តដោយផ្ទាល់ ដូចជាការបង់កម្រៃសេវាជាដើម។ សេវាសម្រាប់ធុរកិច្ចចំនួន ១៦៩[៣] កំពុងត្រូវបានអនុវត្តតាមមធ្យោបាយខាងលើ ដែលការអនុវត្តបែបនេះ នៅបង្កជាបញ្ហាប្រឈមសម្រាប់ធុរជន ក្នុងការស្នើសុំសេវាពាក់ព័ន្ធផ្សេងៗ សម្រាប់បំពេញអនុលោមភាពនៃប្រតិបត្តិការអាជីវកម្ម ដោយសារភាពស្មុគស្មាញនៃនីតិវិធីស្នើសុំសេវា និង ការចំណាយពេល និង ថវិកាច្រើន។

ឆ្លើយតបនឹងបញ្ហាទាំងនេះ, ក្រសួង ស្ថាប័នមួយចំនួន បានរៀបចំផ្តល់សេវាបែបអនឡាញតែម្តង ដែលការរៀបចំនេះអាចបែងចែកបានជា ២ ប្រភេទបន្តទៀតគឺ អនឡាញតែមានប្រព័ន្ធដាច់ដោយឡែកគ្នា និង អនឡាញជាប្រព័ន្ធអេកូឡូស៊ី។ ជាធម្មតា ការចុះបញ្ជីអាជីវកម្ម ឬ ការស្នើសុំអាជ្ញាបណ្ណជំនាញអាចស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធច្រើន ហើយធុរជនមានកាតព្វកិច្ចទៅស្នើសុំពីក្រសួង ស្ថាប័ននីមួយៗ។ បច្ចុប្បន្ន ក្រសួង ស្ថាប័នបានសម្រួលនីតិវិធីទាំងនេះ តាមរយៈការដាក់ឱ្យដំណើរការចុះបញ្ជី ឬ ស្នើសុំអាជ្ញាបណ្ណជំនាញតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានស្ទើរតែទាំងស្រុង តាមក្រសួង ស្ថាប័នរៀងខ្លួន ប៉ុន្តែនៅមិនទាន់បានបើកទិន្នន័យទាំងនោះ ក្នុងការផ្លាស់ប្តូរជាមួយក្រសួង ស្ថាប័នដទៃទេ ព្រោះប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលត្រូវបានរៀបចំឡើង មានលក្ខណៈដាច់ដោយឡែកពីគ្នា។ ដូច្នេះ, ទោះបីជានីតិវិធីស្នើសុំសេវាអាចធ្វើបានតាមបែបអនឡាញនៅក្រសួង ស្ថាប័នមួយក៏ដោយ ធុរជនត្រូវផ្តល់ព័ត៌មានអំពីសហគ្រាស, ម្ចាស់សហគ្រាស ឬ ព័ត៌មានចាំបាច់ដដែលៗ នៅពេលបំពេញពាក្យស្នើសុំនៅក្រសួង ស្ថាប័នផ្សេងទៀត ដែលបង្កភាពស្មុគស្មាញបន្ថែម និង អប្រសិទ្ធភាពការងារ។ និយាយមួយបែបទៀត ការផ្តល់សេវាប្រភេទនេះ គ្រាន់តែផ្លាស់ប្តូរពីភាពស្មុគស្មាញបែបប្រពៃណី (Traditional Complexity) ទៅជាភាពស្មុគស្មាញបែបឌីជីថល (Digital Complexity) ប៉ុណ្ណោះ។

---

[១] ទិន្នន័យគិតត្រឹមថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០២៤ ហើយពុំបានរាប់បញ្ចូលសេវាពាក់ព័ន្ធធុរកិច្ចនៅថ្នាក់ក្រោមជាតិទេ

[២] ជាសេវាថ្នាក់ជាតិ

[៣] ជាសេវាថ្នាក់ជាតិ

ចំណែកការផ្តល់សេវាតាមអនឡាញជាប្រព័ន្ធអេកូឡូស៊ី សំដៅលើការផ្តល់សេវាតាមអនឡាញពេញលេញ ដែលធុរជនអាចស្នើសុំសេវាដែលពាក់ព័ន្ធគ្នា ហើយផ្តល់ព័ត៌មានចាំបាច់ចូលក្នុងប្រព័ន្ធផ្តល់សេវាតែម្តងគត់។ បន្ទាប់មក, ទិន្នន័យចាំបាច់ទាំងនោះ ត្រូវបានចែករំលែក, ផ្ទៀងផ្ទាត់ និង ប្រើប្រាស់នៅក្នុងប្រព័ន្ធអេកូឡូស៊ីរួម ផ្អែកលើការយល់ព្រម (Consent) របស់អ្នកស្នើសុំ តាមរយៈយន្តការអន្តរប្រតិបត្តិការ និង អភិបាលកិច្ចទិន្នន័យច្បាស់លាស់ ដោយមិនចាំបាច់ផ្តល់ព័ត៌មានដដែលៗបន្ថែមទៀតនៅអង្គភាពពាក់ព័ន្ធដទៃទេ។ ការអនុវត្តបែបនេះ បានកាត់បន្ថយនីតិវិធីស្មុគស្មាញ និង បន្ទុកទាំងការចំណាយពេល និង ថវិការបស់ធុរជន។ ជាក់ស្តែង, កម្ពុជាបានអនុវត្តអភិក្រមនេះ លើវិសាលភាពនៃការចុះបញ្ជីអាជីវកម្ម និង ការស្នើសុំអាជ្ញាបណ្ណជំនាញសរុបចំនួន ៣៣ របស់ក្រសួង ស្ថាប័នចូលរួមចំនួន ២១[៤] តាមរយៈការរៀបចំ និង ដាក់ឱ្យប្រើប្រាស់ថ្នាល OBR ជា ៣ ដំណាក់កាល ចាប់តាំងពីឆ្នាំ ២០២០។ ការណ៍នេះ បានអនុញ្ញាតឱ្យសហគ្រាសចុះបញ្ជីអាជីវកម្មជាកញ្ចប់ក្នុងពេលតែមួយ ឬ ស្នើសុំអាជ្ញាបណ្ណជំនាញតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ហើយទិន្នន័យត្រូវបានចែករំលែកទៅកាន់ក្រសួង ស្ថាប័នពាក់ព័ន្ធតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cambodia Data Exchange-CamDX) ដើម្បីពិនិត្យ និង អនុម័តលើពាក្យស្នើសុំទៅតាមសមត្ថកិច្ចរៀងៗខ្លួន ដូចក្នុងរូបភាពទី ១ ខាងក្រោម។

រូបភាពទី១: ប្រព័ន្ធអេកូឡូស៊ីនៃការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន




គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤, សហគ្រាសបានចុះបញ្ជីក្នុងថ្នាល OBR មានចំនួនប្រមាណ ៤២ ពាន់ ជាមួយនឹងដើមទុនវិនិយោគសរុបប្រមាណ ១៥,៦ ប៊ីលានដុល្លារអាមេរិក។ បន្ថែមលើនេះ, អាជ្ញាបណ្ណ លិខិតអនុញ្ញាត និង វិញ្ញាបនបត្រតាមវិស័យ ចំនួនប្រមាណ ២៨ ពាន់ ត្រូវបានអនុម័តដោយក្រសួង ស្ថាប័នជំនាញនីមួយៗនៅក្នុងប្រព័ន្ធអេកូឡូស៊ី ដែលកំពុងធ្វើប្រតិបត្តិការលើថ្នាល CamDX។ ការដាក់ឱ្យប្រើប្រាស់ថ្នាល OBR បានផ្តល់ភាពងាយស្រួលដល់ការបង្កើតអាជីវកម្មដោយ

[៤] គិតត្រឹមខែធ្នូ ឆ្នាំ ២០២៤

ស្របច្បាប់ច្រើនជាងមុន ដោយសហគ្រាសអាចធ្វើការស្នើសុំចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យា-ព័ត៌មានទាំងស្រុង ដែលកាត់បន្ថយតម្រូវការបំពេញព័ត៌មានដដែលៗ, ឯកសារភ្ជាប់ច្រើន និង កម្រៃសេវា។ តាមរយៈកិច្ចខិតខំប្រឹងប្រែង និង សមិទ្ធផលខាងលើ, ថ្នាលឌីជីថលគន្លឹះរបស់រាជរដ្ឋាភិបាលដែលបានគាំទ្រការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច ក៏បានទទួល ជ័យលាភីជាបន្តបន្ទាប់ក្នុងកម្រិតតំបន់ និង អន្តរជាតិផងដែរ។ ជាក់ស្តែង, ថ្នាលទូទាត់សងប្រាក់ឌីជីថលបាគង បានទទួលពានរង្វាន់ផលិតផល និង សេវាកម្មដែលមានឧត្តមភាពប្រចាំឆ្នាំ ២០២១ ពីទស្សនាវដ្តីជប៉ុន Nikkei, ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា CamDX ទទួលបានជ័យលាភីការសម្របខ្លួន ប្រើប្រាស់បច្ចេកវិទ្យាចំហកូដប្រចាំឆ្នាំ ពីកម្មវិធីពានរង្វាន់អនាគតរដ្ឋាភិបាល នៅឆ្នាំ ២០២២, ហើយថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh បានឈ្នះមេដាយមាស នៃពានរង្វាន់ឌីជីថលអាស៊ានឆ្នាំ ២០២៤។

ទោះជាយ៉ាងនេះក្តី, របាយការណ៍ "Business Ready 2024" របស់ធនាគារពិភពលោកដែលបានសិក្សាវាយតម្លៃលើបរិយាកាសអាជីវកម្ម និង ការវិនិយោគតាមប្រទេសក្នុងតំបន់ បានបង្ហាញថាកម្ពុជា នៅមានចំណុចមួយចំនួនដែលគួរកែលម្អបន្ថែម ដោយត្រូវពង្រឹងយន្តការផ្តល់សេវាសាធារណៈជាពិសេសសេវាគាំទ្រធុរកិច្ច តាមរយៈការធ្វើឌីជីថលូបនីយកម្ម ដើម្បីធានាអន្តរប្រតិបត្តិការរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង សាមញ្ញកម្មនីតិវិធីស្នើសុំ សំដៅកាត់បន្ថយតម្រូវការច្រើនពេកក្នុងការបំពេញអនុលោមភាពរបស់ធុរជន។ ដូច្នេះ, លទ្ធផល និង អនុសាសន៍នៃការសិក្សាក្នុងរបាយការណ៍ខាងលើក៏មានសារៈសំខាន់ក្នុងការប្រើប្រាស់ជាមូលដ្ឋានមួយ សម្រាប់ឆ្លុះបញ្ចាំងក្នុងវិធានការគន្លឹះនៃយុទ្ធសាស្ត្រនេះដែរ។

## ២.២- បញ្ហាប្រឈម

ទោះជាការផ្តល់សេវាតាមរយៈប្រព័ន្ធអេកូឡូស៊ីនៃការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យា-ព័ត៌មាននេះ បានចូលរួមសម្រួល និង កាត់បន្ថយបន្ទុករបស់ធុរជនក្នុងការស្នើសុំសេវាពាក់ព័ន្ធធុរកិច្ចបានច្រើនក៏ដោយ ការអនុវត្តការងារកន្លងទៅ នៅបន្តជួបប្រទះបញ្ហាចម្បងដូចខាងក្រោម៖

### ១- ភាពស្មុគស្មាញនៃសេវា និង នីតិវិធីស្នើសុំសេវាសម្រាប់ធុរកិច្ច

ក្រសួង ស្ថាប័ន មានសេវាសម្រាប់ធុរកិច្ចច្រើន ដែលតម្រូវឱ្យធុរជនស្នើសុំពីក្រសួង ស្ថាប័នពាក់ព័ន្ធច្រើន ដើម្បីបំពេញអនុលោមភាពនៃការធ្វើនិយ័តកម្មទៅតាមវិស័យ។ សេវាមួយចំនួន ក៏អាចមានលក្ខណៈប្រហាក់ប្រហែលគ្នាផងដែរ ដោយសារការរៀបចំបញ្ជីសេវាសម្រាប់ធុរកិច្ចជាខ្សែច្រវាក់ច្បាស់លាស់ ដែលអាចបង្ហាញពីភាពអាស្រ័យ (Dependencies) រវាងសេវានីមួយៗ ក្រោមក្រសួងស្ថាប័នផ្សេងគ្នា នៅមិនទាន់បានអនុវត្តក្នុងក្របខ័ណ្ឌរួមនៅឡើយ។

ម្យ៉ាងវិញទៀត, នីតិវិធីនៃការស្នើសុំសេវាមួយចំនួននៅតាមក្រសួង ស្ថាប័ន នៅមានភាព-ស្មុគស្មាញ ដូចជាតម្រូវការបំពេញព័ត៌មាន និង ឯកសារភ្ជាប់ច្រើន, ការចុះពិនិត្យទីតាំងដោយផ្ទាល់សម្រាប់ប្រភេទអាជីវកម្មដែលមិនចាំបាច់ ឬ អាចលើកលែងបាន និង នីតិវិធីសាំញ៉ាំច្រើន ក្នុងការអនុម័តផ្តល់អាជ្ញាបណ្ណជំនាញ លិខិតអនុញ្ញាត និង វិញ្ញាបនបត្រ ដែលបង្កការលំបាកដល់ធុរជនក្នុងការស្នើសុំ។ ភាពស្មុគស្មាញទាំងនេះ ក៏អាចជាកត្តារាំងមួយ ក្នុងការបំពេញអនុលោមភាពរបស់ធុរជនផងដែរ។

**២- កង្វះស្តង់ដា និង គោលការណ៍ណែនាំបច្ចេកទេសរួមសម្រាប់រៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន**

ក្រសួង ស្ថាប័ន អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានមុខងារផ្សេងៗគ្នា ទៅតាមស្ថានភាព និង តម្រូវការជាក់ស្តែង ស្របតាមប្រភេទនៃសេវាសាធារណៈក្រោមសមត្ថកិច្ចរបស់ខ្លួន ដោយផ្តោតតែលើ **មុខងារតម្រូវការ** (Functional Requirement)។ ដោយឡែក មុខងារសំខាន់ៗដទៃទៀតសម្រាប់ដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលជា **មុខងារមិនតម្រូវការ** (Non-Functional Requirement) សម្រាប់ការធ្វើការជាមួយប្រព័ន្ធផ្សេងទៀតនោះ មិនទាន់ត្រូវបានផ្តល់ការយកចិត្តទុកដាក់នោះទេ ហើយជម្រើសនៃការប្រើប្រាស់បច្ចេកវិទ្យា (Technology) ផ្សេងគ្នា ក្នុងការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក៏មិនទាន់បានកំណត់ច្បាស់លាស់។

**មុខងារមិនតម្រូវការ** ដើរតួនាទីចម្បង ក្នុងការធានានូវអន្តរប្រតិបត្តិការរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ភាពខុសគ្នាលើការប្រើប្រាស់មុខងារទាំងនេះ បានបង្កើតជាស្តង់ដាច្រើន សម្រាប់យកទៅអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅតាមក្រសួង ស្ថាប័ន ក្នុងការផ្តល់សេវាសាធារណៈ ដែលបានបង្កជាបញ្ហាប្រឈមក្នុងការអនុវត្តអភិក្រម "**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**" ក្នុងន័យថាប្រតិបត្តិការនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងនោះ នៅបែកខ្ញែកពីគ្នា។ ដូច្នេះ, កង្វះស្តង់ដា និង គោលការណ៍បច្ចេកទេសរួមក្នុងការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន បាន និង កំពុងបង្កបញ្ហាប្រឈមលើការធ្វើអន្តរប្រតិបត្តិការរវាងប្រព័ន្ធរបស់ក្រសួង ស្ថាប័ន, ចំណាយថវិកាច្រើន និង ច្រំដែល សម្រាប់វិនិយោគលើបច្ចេកវិទ្យាដែលអាចប្រើប្រាស់ធនធានមានស្រាប់ ជាមួយនឹងចំណាយខ្ពស់ក្នុងការថែទាំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលប្រើប្រាស់បច្ចេកវិទ្យាចាស់ (Legacy Technology) ជាដើម។

**៣- ភាពមានកម្រិតក្នុងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថលតាមក្រសួង ស្ថាប័ន**

ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល (Digital Public Infrastructure-DPI) ជាហេដ្ឋារចនាសម្ព័ន្ធឌីជីថលរួម (Shared Digital Infrastructure) ប្រៀបដូចជា ទឹក, ផ្លូវ និង ភ្លើង បង្កើតឡើងក្នុងគោលបំណងគាំទ្រការផ្តល់សេវាសាធារណៈតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងៗ ក្នុងទម្រង់ជាអេកូឡូស៊ីឌីជីថលមួយ ប្រកបដោយសុវត្ថិភាព, ស័ក្តិសិទ្ធភាព និង បំពេញឱ្យគ្នាទៅវិញទៅមក។ ម្យ៉ាងទៀត DPI ក៏ជាថ្នាលឌីជីថលគ្រឹះ ជំរុញការធ្វើអន្តរសកម្មរវាងតួអង្គផ្សេងៗ តាមរយៈយន្តការអន្តរប្រតិបត្តិការ សំដៅលើកកម្ពស់នវានុវត្តន៍ ក្នុងបរិស្ថានឌីជីថលរស់រវើកនៃប្រព័ន្ធអេកូឡូស៊ីរួម។

កម្ពុជាមានថ្នាលឌីជីថលគ្រឹះដែលជា DPI ដូចជា ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX), ថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា (Cambodia Digital Key-CamDigiKey), ថ្នាលទូទាត់សងប្រាក់ឌីជីថលបាគង (Bakong) និង ថ្នាលផ្ទៀងផ្ទាត់ឯកសារ (verify.gov.kh)។ បច្ចុប្បន្នការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថលទាំងនេះ មិនទាន់មានភាពទូលំទូលាយនៅឡើយសម្រាប់យកទៅអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ផ្តល់សេវាសាធារណៈរបស់ក្រសួង ស្ថាប័នមួយចំនួន ដោយសារម្យ៉ាងការយល់ដឹងអំពី DPI និង សមត្ថភាពបច្ចេកទេសក្នុងការប្រើប្រាស់បច្ចេកវិទ្យាទាំងនេះនៅមានកម្រិត ហើយម្យ៉ាងទៀតទស្សនាទាននៃ DPI ក៏ថ្មីសម្រាប់កម្ពុជាផងដែរ។

**៤- កង្វះការរៀបចំ និង ការចែករំលែកទិន្នន័យគោលនៅតាមក្រសួង ស្ថាប័ន**

ទិន្នន័យគោល (Base Registry) គឺជាប្រភពទិន្នន័យ ឬ មូលដ្ឋានសម្រាប់ការគ្រប់គ្រងប្រទេស ហើយដែលអាចចែកចេញជា ៣ ក្រុមធំៗ គឺ ទិន្នន័យគោលអាជីវកម្ម (Business), ទិន្នន័យគោលរូបវន្តបុគ្គល (Individual) និង ទិន្នន័យគោលទ្រព្យសម្បត្តិ (Property)។ ក្រៅពីការប្រើប្រាស់សម្រាប់ការគ្រប់គ្រង, ទិន្នន័យគោលទាំងនេះ ក៏ត្រូវបានប្រើប្រាស់សម្រាប់គាំទ្រការផ្តល់សេវាសាធារណៈរបស់រដ្ឋាភិបាលដែរ។ ក្រសួង ស្ថាប័នមួយចំនួន ដែលមានសមត្ថកិច្ចគ្រប់គ្រងទិន្នន័យគោលសំខាន់ៗទាំងនោះ បានកសាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់កត់ត្រា ប៉ុន្តែគុណភាពនៃទិន្នន័យមួយចំនួននៅមានកម្រិត ហើយទិន្នន័យទាំងនោះ មិនទាន់ត្រូវបានចែករំលែក និង ផ្លាស់ប្តូរដោយស្វ័យប្រវត្តិ ឱ្យបានទូលំទូលាយនៅឡើយទេ។

**៥- កង្វះការផ្សព្វផ្សាយព័ត៌មាន និង ការបញ្ជ្រាបការយល់ដឹង**

ការរៀបចំ និង ផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធសេវាសាធារណៈសម្រាប់ធុរកិច្ច ជាពិសេសព័ត៌មានអំពីការបំពេញអនុលោមភាពពេញលេញ ដែលស្របតាមបទប្បញ្ញត្តិគ្រប់ប្រភេទនៃការធ្វើនិយ័តកម្មដើម្បីដំណើរការអាជីវកម្មមួយបាន នៅមិនទាន់ត្រូវបានអនុវត្តជាប្រចាំនៅឡើយ។ ភាពមិនច្បាស់លាស់ ឬ មិនពេញលេញទាំងនេះ បានបង្កជាបញ្ហាប្រឈមដល់ធុរជនមួយចំនួន ក្នុងការបំពេញអនុលោមភាព។

## ២.៣- បទពិសោធជាអន្តរជាតិ

បណ្តាប្រទេសក្នុងតំបន់ និង សកល បាន និង កំពុងជួបបញ្ហាប្រឈមពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ចប្រហាក់ប្រហែលគ្នានឹងស្ថានភាពរបស់កម្ពុជាដែរ រួមមាន៖ នីតិវិធីរដ្ឋបាលនៃការស្នើសុំសេវាមានភាពស្មុគស្មាញ, សេវាមួយចំនួនមានភាពជាន់គ្នា និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្តល់សេវាសម្រាប់ធុរកិច្ចមានភាពបែកខ្ញែកគ្នាជាដើម។ ក្នុងនោះ បទពិសោធរបស់ប្រទេសមួយចំនួនដូចជា សិង្ហបុរី ម៉ាឡេស៊ី និង បារាំង បានបង្ហាញពីលទ្ធភាពនៃការដោះស្រាយបញ្ហា តាមរយៈការដាក់ចេញនូវវិធានការកែទម្រង់ស៊ីជម្រៅ និង ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន។

ថ្នាល GoBusiness នៅសិង្ហបុរីត្រូវបានរៀបចំឡើង ដើម្បីប្រមូលផ្តុំសេវាសាធារណៈរបស់ក្រសួង ស្ថាប័នសំខាន់ៗ ដោយចាប់ផ្តើមពីសេវាក្នុងវិស័យចំណីអាហារ និង ភេសជ្ជៈ ដែលមានតម្រូវការញឹកញាប់ជាងគេ និង ពង្រីកបន្ថែមសេវាក្នុងវិស័យពាក់ព័ន្ធផ្សេងទៀតជាបន្តបន្ទាប់។ បច្ចុប្បន្ន នៅលើថ្នាលនេះ ធុរជនអាចស្វែងរកព័ត៌មានអំពីសេវាពាក់ព័ន្ធនឹងធុរកិច្ចជាង ៣០០ របស់ក្រសួង ស្ថាប័នជាង ៤០ និង អាចស្នើសុំអាជ្ញាបណ្ណច្រើនប្រភេទ តាមរយៈការបំពេញពាក្យស្នើសុំរួម (Integrated Application Form) មួយ ដែលមានលក្ខណៈសាមញ្ញ និង តម្រូវឱ្យបំពេញព័ត៌មានតិច[៥]។ បន្ថែមលើនេះ, ស្តង់ដាបច្ចេកទេសកម្រិតរដ្ឋាភិបាល (Government Tech Stack) ត្រូវបានរៀបចំ និង ដាក់ឱ្យអនុវត្តដើម្បីធានាថា ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្តល់សេវាសម្រាប់ធុរកិច្ច ត្រូវបានអភិវឌ្ឍស្របតាម

[៥] ចំណុចទិន្នន័យចំនួន ៨៤៥ ក្នុង ១៤ ទម្រង់ស្នើសុំផ្សេងគ្នា ត្រូវបានកាត់មកត្រឹមចំនួន ៩០ ចំណុចទិន្នន័យ លើទម្រង់ស្នើសុំរួមតែមួយ ព្រោះទិន្នន័យដែលទទួលបានពីធុរជន ត្រូវបានចែករំលែកជូនទៅក្រសួង ស្ថាប័នដើម្បីត្រួតពិនិត្យ និង ចេញអាជ្ញាបណ្ណ, ព្រមទាំងអាចត្រួតពិនិត្យអនុលោមភាពរបស់ខ្លួនផងដែរ។

គោលការណ៍រួម និង អាចធ្វើអន្តរប្រតិបត្តិការក្នុងប្រព័ន្ធអេកូឡូស៊ី ប្រកបដោយប្រសិទ្ធភាព។ គំនិតផ្តួចផ្តើមទាំងនេះ បានកាត់បន្ថយពេលក្នុងការទទួលបានអាជ្ញាបណ្ណក្នុងវិស័យចំណីអាហារ និង ភេសជ្ជៈជាមធ្យមពីចន្លោះ ១២ ទៅ ១៦ សប្តាហ៍ មកតិចជាង ៤ សប្តាហ៍[៦]។ ការណ៍នេះ បានសម្រួលបន្ទុកអនុលោមភាពរបស់ធុរជនមួយផ្នែកធំ ដែលរួមចំណែកដល់ការបង្កើតបរិយាកាសអំណោយផលសម្រាប់ធុរកិច្ច ក្នុងវិស័យនេះដែលភាគច្រើនជាសហគ្រាសធុនតូច និងមធ្យមផង និង បរិយាកាសសេដ្ឋកិច្ច និង វិនិយោគជារួមផង។

ចំណែកឯម៉ាឡេស៊ីវិញ បានប្រើប្រាស់អភិក្រមវះកាត់ (Regulatory Guillotine Approach) ដើម្បីពិនិត្យឡើងវិញ និង កែសម្រួលបទប្បញ្ញត្តិពាក់ព័ន្ធនឹងសេវាសាធារណៈសម្រាប់ធុរកិច្ច ដោយផ្តោតលើការលុបចេញ ឬ ផ្គួបចូលគ្នានូវសេវាដែលស្ទួនគ្នា ឬ មិនមានតម្លៃបន្ថែមខ្ពស់។ ជាមួយគ្នានេះ, ធុរជនអាចស្នើដាក់ពាក្យស្នើសុំអាជ្ញាបណ្ណច្រើនក្នុងពេលតែមួយ និង តាមដានដំណើរការនៃពាក្យស្នើសុំយ៉ាងងាយស្រួល តាមរយៈការប្រើប្រាស់ថ្នាលផ្តល់អាជ្ញាបណ្ណតាមប្រព័ន្ធអនឡាញ ដែលមានឈ្មោះថា Business Licensing Electronic Support System (BLESS)[៧]។ ជាលទ្ធផលនៃការកែទម្រង់ស៊ីជម្រៅគួបផ្សំនឹងការប្រើប្រាស់ប្រព័ន្ធ BLESS, ចំនួនអាជ្ញាបណ្ណនៅម៉ាឡេស៊ី ប្រមាណ ៣៦% ត្រូវបានកាត់បន្ថយ (Streamlined)។ ដូចគ្នានេះដែរ, បារាំង បានរៀបចំ និង ដាក់ដំណើរការថ្នាល entreprendre.service-public.fr រួមសម្រាប់ធុរជន ក្នុងការស្វែងរកព័ត៌មាន ឬ ស្នើសុំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ប្រកបដោយប្រសិទ្ធភាព។ សេវាសាធារណៈគាំទ្រធុរកិច្ចទាំងនេះ ត្រូវបានឆ្លងកាត់ការសិក្សាស្វែងរកភាពជាន់គ្នា (Redundancy Test) និង ការធ្វើសាមញ្ញកម្មនីតិវិធីស្នើសុំសេវាស៊ីជម្រៅ ដើម្បីធានាលុបចោលភាពត្រួតស៊ីគ្នានៃសេវា និង កាត់បន្ថយជាអតិបរមានូវភាពស្មុគស្មាញនៃនីតិវិធីស្នើសុំស្របតាមតាមគោលការណ៍ "ប្រាប់តែមួយលើក" ("Dites-le-nous une fois" ឬ "Tell us once")[៨]។

ក្នុងន័យនេះ, ដើម្បីធានាភាពជោគជ័យនៃការអនុវត្តអភិក្រម **"ជវភាពនៃប្រព័ន្ធតួអង្គតែមួយ"** នៅក្នុងក្របខ័ណ្ឌនៃការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច និង ស្របតាមបទពិសោធជាអន្តរជាតិ, ការរៀបចំយុទ្ធសាស្ត្រកម្រិតរាជរដ្ឋាភិបាល ដែលរំលេចពីក្របខ័ណ្ឌរួមសម្រាប់រៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចរបស់ក្រសួង ស្ថាប័ន ពិតជាមានភាពចាំបាច់។ ផ្អែកលើក្របខ័ណ្ឌរួមនេះ, ក្រសួង ស្ថាប័នត្រូវចូលរួមរៀបចំសេវាសាធារណៈសម្រាប់ធុរកិច្ច ជាពិសេសក្នុងទិដ្ឋភាពចំនួន ២ សំខាន់ គឺ ការពិនិត្យឡើងវិញ និង កែសម្រួលសេវា និង នីតិវិធីស្នើសុំ, និង ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានស្តង់ដាររួមគ្នាក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលតែមួយ ដើម្បីធានាបានប្រសិទ្ធភាពនៃការវិនិយោគ ដែលគាំទ្រយន្តការផ្តល់សេវាសាធារណៈពាក់ព័ន្ធធុរកិច្ចប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, សុវត្ថិភាព និង តម្លាភាព ព្រមទាំងលើកកម្ពស់ការបំពេញអនុលោមភាពផងដែរ។

---

[៦] gobusiness.gov.sg/

[៧] bless2.bless.gov.my/bless2/public/publicRegistration

[៨] numerique.gouv.fr/services/guichet-dites-le-nous-une-fois/

# ៣- ក្របខ័ណ្ឌរួមនៃយុទ្ធសាស្ត្រ

## ៣.១- ចក្ខុវិស័យ គោលបំណង និង គោលដៅ

ដើម្បីដោះស្រាយបញ្ហាប្រឈម និង ពង្រឹងបន្ថែមនូវវិធានការអន្តរាគមន៍ ស្របតាមទិសដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល, **«យុទ្ធសាស្ត្រស្ដីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨»** បានដាក់ចេញនូវចក្ខុវិស័យ **"ចូលរួមបង្កើតបរិយាកាសអំណោយផលសម្រាប់ការធ្វើធុរកិច្ច តាមរយៈការផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ដែលមានប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, និង តម្លាភាព ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង"**។ ស្របតាមចក្ខុវិស័យខាងលើ, យុទ្ធសាស្ត្រនេះមានគោលបំណង **"បង្កើតប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច ប្រកបដោយភាពរស់រវើក, ភាពធន់, ប្រទាក់ក្រឡា និង បំពេញឱ្យគ្នាទៅវិញទៅមក សំដៅពង្រឹងប្រសិទ្ធភាពនៃយន្តការផ្តល់សេវា-សាធារណៈសម្រាប់ធុរកិច្ច និង លើកកម្ពស់ការបំពេញអនុលោមភាព"**។

ឆ្លើយតបនឹងចក្ខុវិស័យ និង គោលបំណងខាងលើ, យុទ្ធសាស្ត្រនេះ បានកំណត់នូវគោលដៅចំនួន ៤ ដូចខាងក្រោម៖

- **ទី១-** កែសម្រួល ឬ លុបចេញសេវា និង នីតិវិធីការងារក្នុងការស្នើសុំសេវាដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ឬ មិនមានតម្លៃបន្ថែមខ្ពស់ ដើម្បីបង្រួម និង ធានាភាពងាយស្រួលក្នុងការស្នើសុំសេវាសម្រាប់ធុរកិច្ចដល់ធុរជន
- **ទី២-** កសាង និង អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្តល់សេវាអេឡិចត្រូនិក ឱ្យដំណើរការនៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច ផ្អែកលើគោលការណ៍ប្រសិទ្ធភាពនៃការវិនិយោគ
- **ទី៣-** ធ្វើអាទិភាវូបនីយកម្មសេវាសម្រាប់ធុរកិច្ចផ្អែកលើភាពចាំបាច់ និង តម្រូវការខ្ពស់ និង ដាក់ឱ្យដំណើរការសេវាចំនួន ៨០% នៃសេវាអាទិភាពទាំងនោះតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានត្រឹមឆ្នាំ ២០២៨
- **ទី៤-** ផ្សព្វផ្សាយព័ត៌មាន និង បញ្ជ្រាបការយល់ដឹងអំពីសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ដើម្បីលើកកម្ពស់ការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធ។

## ៣.២- និយមន័យ និង វិសាលភាព

សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច សំដៅដល់សេវាសាធារណៈដែលផ្តល់ការគាំទ្រដល់ធុរកិច្ចដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានជាគោល នៅគ្រប់ដំណាក់កាលនៃវដ្តធុរកិច្ច រាប់ចាប់ពីការបង្កើតការធ្វើប្រតិបត្តិការ ការផ្អាក រហូតដល់ការបិទអាជីវកម្ម រួមមានជាអាទិ៍ ការចុះបញ្ជី, ការស្នើសុំអាជ្ញាបណ្ណជំនាញ, លិខិតអនុញ្ញាត, វិញ្ញាបនបត្រ ឬ សេវាផ្សេងៗ។ សេវាពាក់ព័ន្ធទាំងនេះ ជាសេវាប្រតិបត្តិការ (Transactional Services) ដែលតម្រូវឱ្យមានសកម្មភាពចាប់ពី ការទទួលពាក្យស្នើសុំ, ការបង់កម្រៃសេវា, ការពិនិត្យ និង ការអនុម័តលើពាក្យស្នើសុំរបស់មន្ត្រីអនុវត្ត ជា**ទម្រង់អនឡាញពេញលេញ នៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច** សំដៅលើកកម្ពស់ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព និង តម្លាភាពនៃការផ្តល់សេវា។ ដើម្បីងាយស្រួលក្នុងការអនុវត្តការងារនៅក្នុងយុទ្ធសាស្ត្រនេះឱ្យមានសង្គតិភាព, ក្រសួង

ស្ថាប័នទាំងអស់ ត្រូវទទួលស្គាល់ និង ឯកភាពគ្នានូវនិយមន័យរួមនៃ **"សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច"** នេះ។ សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចក្នុងយុទ្ធសាស្ត្រនេះ មានវិសាលភាពគ្របដណ្តប់រាល់សេវា ដែលបម្រើដល់វិស័យធុរកិច្ច ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ។

## ៣.៣- ប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច

រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលការណ៍តម្រូវឱ្យគ្រប់ក្រសួង ស្ថាប័ន ក្រោមការដឹកនាំ និងសម្របសម្រួលរបស់គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល បន្តខិតខំរៀបចំដាក់បញ្ចូលសេវាសម្រាប់ធុរកិច្ចដែលមានតម្រូវការខ្ពស់ជាសេវាអេឡិចត្រូនិក និង រៀបចំជាក្របខ័ណ្ឌរួមមួយដែលមានឈ្មោះថា **"ប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច"** សំដៅកែលម្អបរិយាកាសធុរកិច្ច និង ទាក់ទាញអ្នក-វិនិយោគមកកម្ពុជា។ ប្រព័ន្ធអេកូឡូស៊ីឌីជីថល គឺជាបណ្តាញប្រទាក់ក្រឡា (Complex Network) នៃមនុស្ស ឬ ស្ថាប័ន, ធុរកិច្ច និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ធ្វើអន្តរសកម្មជាមួយគ្នា ដោយប្រកាន់ខ្ជាប់គោលការណ៍ច្បាស់លាស់ ដើម្បីសម្រេចគោលបំណងជាក់លាក់ណាមួយ។ ដូច្នេះ, **"ប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច"** ក្នុងយុទ្ធសាស្ត្រនេះ សំដៅលើអន្តរសកម្ម និង ការបំពេញមុខងារទៅវិញទៅមករវាងក្រសួង ស្ថាប័នគ្រប់វិស័យជាតួអង្គតែមួយ ជាមួយតួអង្គពាក់ព័ន្ធដទៃទៀតនៅក្នុងបរិស្ថានឌីជីថលមួយ ដើម្បីបង្កើតបទពិសោធល្អក្នុងការផ្តល់សេវាសាធារណៈគាំទ្រធុរកិច្ចប្រកបដោយតម្លាភាព, ប្រសិទ្ធ-ភាព, ស័ក្តិសិទ្ធភាព និង ភាពប្រទាក់ក្រឡា ក្នុងន័យលើកកម្ពស់ការបំពេញអនុលោមភាពរបស់ធុរជនដូចមានក្នុងរូបភាពទី ២។

### ៣.៣.១- តួអង្គសំខាន់ និង អន្តរសកម្ម

ការកសាងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច ប្រកបដោយប្រសិទ្ធភាព និង ចីរភាពទាមទារឱ្យមានការចូលរួមពីសមាសភាពតួអង្គសំខាន់ៗ ដែលអន្តរសកម្មក្នុងទម្រង់ផ្សេងគ្នា តាមរយៈការប្រើប្រាស់ទិន្នន័យ និង ថ្នាលឌីជីថល។ ក្នុងនោះ អន្តរសកម្មរវាងតួអង្គនៃក្រសួង ស្ថាប័នផ្តល់សេវា, ធុរជន ឬ អ្នកស្នើសុំសេវា និង វិស័យឯកជន បង្កើតបានជាបទពិសោធមួយក្នុងការរៀបចំ និង ធ្វើនវា-នុវត្តន៍សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច តាមរយៈយន្តការការងារច្បាស់លាស់។ ដើម្បីរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច, ក្រសួង ស្ថាប័នត្រូវផ្តល់កិច្ចសហការ ជាពិសេសជាមួយក្រសួង ស្ថាប័នផ្សេងទៀត ក្នុងការពិនិត្យឡើងវិញ និង កែសម្រួលនីតិវិធីការងារនៅក្នុងការផ្តល់សេវា ដោយកាត់ចេញនីតិវិធីណាដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ឬ មិនមានតម្លៃបន្ថែមខ្ពស់ និង ធ្វើអាទិភាវូបនីយកម្មសេវាដែលមានតម្រូវការខ្ពស់ពីវិស័យឯកជន តាមរយៈការធ្វើឌីជីថលូបនីយកម្មសេវាទាំងនោះ ដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្តល់សេវា ត្រូវគោរពតាមវិធាន និង គោលការណ៍ច្បាស់លាស់ ដោយប្រើប្រាស់ធនធានមានស្រាប់ សំដៅធានាបានប្រសិទ្ធភាពនៃការវិនិយោគ ក្នុងគោលបំណងពង្រឹងអន្តរប្រតិបត្តិការ និង ការផ្លាស់ប្តូរទិន្នន័យរវាងក្រសួង ស្ថាប័នដើម្បីជំរុញនវានុវត្តន៍នៅក្នុងប្រព័ន្ធអេកូឡូស៊ីទាំងមូល។

រូបភាពទី២: អន្តរសេកម្មក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច




បន្ថែមលើនេះ, អ្នកស្នើសុំសេវា មានអន្តរសេកម្មជាមួយក្រសួង ស្ថាប័នផ្តល់សេវា តាមរយៈការ-ប្រើប្រាស់ថ្នាលបណ្តុំព័ត៌មានកណ្តាលមួយ ដែលភ្ជាប់ទៅគ្រប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្តល់សេវារបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។ ថ្នាលបណ្តុំព័ត៌មានកណ្តាលនេះ ដើរតួនាទីសំខាន់ ក្នុងការជួយសម្រួល និងគាំទ្រអ្នកស្នើសុំសេវា ដើម្បីស្វែងរកព័ត៌មានអំពីសេវាអេឡិចត្រូនិកគាំទ្រធុរកិច្ច និង ការពិនិត្យអនុលោម-ភាពប្រកបដោយតម្លាភាព និង ស័ក្តិសិទ្ធភាពខ្ពស់។ ជាមួយគ្នានេះ, តួអង្គពាក់ព័ន្ធដទៃទៀតក្នុងវិស័យឯកជន ដែលជាអ្នកផ្តល់សេវាកម្មឌីជីថល ដូចជាគ្រឹះស្ថានហិរញ្ញវត្ថុជាដើម ក៏អាចប្រើប្រាស់ថ្នាលបណ្តុំព័ត៌មាននេះ ក្នុងការផ្ទៀងផ្ទាត់ និង ពិនិត្យអនុលោមភាពរបស់អតិថិជនផងដែរ ដែលនឹងអាចជំរុញការរៀបចំ និង ធ្វើទំនើបកម្មនវានុវត្តន៍សេវាកម្មឌីជីថលបន្តរបស់វិស័យឯកជន។

ក្រៅពីនេះ, ដើម្បីគាំទ្រ និង ជំរុញប្រតិបត្តិការនៃការផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួង ស្ថាប័ន មានភារកិច្ចផ្តល់កិច្ចសហការក្នុងការអភិវឌ្ឍសមត្ថភាពមន្ត្រីប្រតិបត្តិ, ផ្សព្វផ្សាយ និង ផ្តល់ការគាំទ្រដល់អ្នកស្នើសុំ ក្នុងន័យធ្វើឱ្យប្រសើរឡើងនូវដំណើរភាព (Dynamics) នៃប្រព័ន្ធអេកូឡូស៊ីនេះផងដែរ។ ជារួម, ភាពស៊ីចង្វាក់នៃអន្តរសេកម្មរវាងតួអង្គទាំងអស់ គួបផ្សំជាមួយហេដ្ឋារចនាសម្ព័ន្ធឌីជីថលគាំទ្រដែលរឹងមាំ នឹងបង្កើតបានជាប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ចដ៏រស់រវើក ដែលបង្កបរិយាកាសអំណោយផលដល់ការធ្វើធុរកិច្ច និង ទាក់ទាញការវិនិយោគនៅកម្ពុជា។

### ៣.៣.២- គោលការណ៍នៃការកសាងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច

ការកសាងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច ត្រូវឈរលើគោលការណ៍បច្ចេកទេសចំនួន ៣ ស្របតាមឯកសារគោលនយោបាយជាធរមាន និង គោលការណ៍ជាក់លាក់ចំនួន ២ បន្ថែមទៀត ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ។ គោលការណ៍ទាំងនេះ មានដូចខាងក្រោម៖

**ទី១- គោលការណ៍បញ្ចូលទិន្នន័យតែមួយលើក** (The Once-Only Principle): ជាគោលការណ៍ផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចដែលតម្រូវឱ្យក្រសួង ស្ថាប័ន ឬ អ្នកស្នើសុំសេវា ផ្តល់ទិន្នន័យតែមួយលើក ដល់អាជ្ញាធរ និង ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដោយមិនស្នើសុំ ឬ តម្រូវឱ្យផ្តល់ទិន្នន័យដដែលច្រើនលើកទេ។ ក្នុងន័យនេះ ក្រសួង ស្ថាប័ន ត្រូវបើកចំហទិន្នន័យគោលរបស់ខ្លួន ដើម្បីចែករំលែកទិន្នន័យជាមួយក្រសួង ស្ថាប័នដទៃផង។ គោលការណ៍នេះ ជួយកាត់បន្ថយការបញ្ចូលទិន្នន័យដែលគ្មានសង្គតិភាព និង សម្រួលបន្ទុករបស់អ្នកស្នើសុំក្នុងការបំពេញពាក្យស្នើសុំ ព្រមទាំងជួយសម្រួលដល់ក្រសួង ស្ថាប័ន ក្នុងការប្រមូល, រក្សាទុក និង ប្រើប្រាស់ទិន្នន័យ អនុលោមតាមអភិបាលកិច្ចទិន្នន័យច្បាស់លាស់។

**ទី២- គោលការណ៍អន្តរប្រតិបត្តិការជាប្រព័ន្ធអេកូឡូស៊ីតែមួយ** (Interoperability as an Ecosystem Principle): ធានាថាគ្រប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង ស្ថាប័នផ្តល់សេវាសម្រាប់ធុរកិច្ច អាចមានប្រតិបត្តិការឯករាជ្យក្នុងការផ្តល់សេវាក្នុងទម្រង់អេឡិចត្រូនិក ព្រមទាំងអាចធ្វើអន្តរប្រតិបត្តិការជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់បណ្តាក្រសួង ស្ថាប័នដទៃទៀត ប្រកបដោយសុវត្ថិភាព ស្របតាមអភិក្រម "**ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ**"។ ដូចនេះ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ផ្តល់សេវារបស់ក្រសួង ស្ថាប័នអាចធ្វើការជាប្រព័ន្ធអេកូឡូស៊ីមួយ តាមរយៈអភិបាលកិច្ចទិន្នន័យ និង ការបើកចំហទិន្នន័យ (Open Data) ដោយមានការតភ្ជាប់រវាងប្រព័ន្ធ និង ការផ្លាស់ប្តូរទិន្នន័យ ដើម្បីបំពេញមុខងារឱ្យគ្នាទៅវិញទៅមក ក្នុងការបម្រើសេវាសាធារណៈប្រកបដោយប្រសិទ្ធភាព។

**ទី៣- គោលការណ៍ផ្តួចផ្តើម និង ពង្រីកដើម្បីប្រសិទ្ធផល** (Land and Expand for Efficiency Principle): ការរៀបចំអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ដោយចាប់ផ្តើមពីតូច ផ្អែកលើកត្តាជោគជ័យ និង ពង្រីកទៅធំ សម្រាប់បំពេញតម្រូវការក្នុងការគ្រប់គ្រង និង ផ្តល់សេវាសាធារណៈ ប្រកបដោយប្រសិទ្ធផល។ ការផ្តួចផ្តើមរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវផ្តោតលើចំណុចអាទិភាពចាំបាច់ និង ប្រសិទ្ធភាពជាគន្លឹះ ទើបអាចពង្រីកវិសាលភាពតាមរយៈការប្រើប្រាស់ធនធានដែលមានស្រាប់ (Reusability) ឬ ពង្រីកបន្ថែម ដើម្បីចែករំលែកការប្រើប្រាស់ជាមួយប្រព័ន្ធផ្សេងៗ ដោយធានាបាននូវប្រសិទ្ធផល និង សន្តិសុខនៃប្រព័ន្ធទាំងមូល។

**ទី៤- គោលការណ៍គាំទ្រធុរកិច្ចជាចម្បង** (Pro-business Principle): ផ្តោតលើការរៀបចំរចនាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង ផ្តល់សេវាសម្រាប់ធុរកិច្ចរបស់ក្រសួង ស្ថាប័ន ផ្អែកលើបទពិសោធរបស់ធុរជន ដែលជាអ្នកប្រើប្រាស់ សំដៅបង្កភាពងាយស្រួល, ភាពទាក់ទាញ និង ភាពពេញចិត្តរបស់អ្នកប្រើប្រាស់ ដោយរួមបញ្ចូលនូវធាតុសំខាន់ៗដូចជា តម្រូវការ និង ទម្លាប់របស់អ្នកប្រើប្រាស់ជាដើម។ គោលការណ៍នេះ តម្រូវឱ្យក្រសួង ស្ថាប័នប្រកាន់ខ្ជាប់នូវផ្នត់គំនិតគាំទ្រធុរកិច្ចគ្រប់រូបភាព ទាំងក្នុង

ការរៀបចំសេវា, ការកំណត់នីតិវិធីស្នើសុំ និង ការផ្តល់សេវាទាំងនោះតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីឆ្លើយតបតម្រូវការជាក់ស្តែងរបស់ធុរកិច្ច សំដៅកាត់បន្ថយរបាំងរារាំងផ្សេងៗ ក្នុងការបំពេញអនុលោមភាពរបស់ធុរជន។

**ទី៥- គោលការណ៍ឧត្តមភាពនៃប្រតិបត្តិការ** (Operational Excellence Principle): សំដៅលើការប្រតិបត្តិល្អប្រសើររបស់មន្ត្រីផ្តល់សេវានៅតាមក្រសួង ស្ថាប័ន ក្នុងការគាំទ្រតម្រូវការរបស់អ្នកស្នើសុំ។ តាមរយៈការអនុវត្តគោលការណ៍នេះ មន្ត្រីផ្តល់សេវានៅតាមក្រសួង ស្ថាប័នត្រូវបង្កើនសមត្ថភាព និង ពង្រឹងក្រមសីលធម៌វិជ្ជាជីវៈឱ្យបានម៉ឺងម៉ាត់ ដើម្បីធានាបានភាពស្អាតស្អំ, តម្លាភាព និង គុណភាពនៃការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច។

រូបភាពទី៣: គោលការណ៍នៃការរៀបចំប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច




## ៣.៤- អាទិភាពជាយុទ្ធសាស្ត្រ

ដើម្បីឈានឆ្ពោះទៅសម្រេចបានការរៀបចំប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច គាំទ្រដល់ការផ្តល់សេវាសម្រាប់ធុរកិច្ច ប្រកបដោយភាពរស់រវើក, ភាពធន់, ប្រទាក់ក្រឡា និង បំពេញឱ្យគ្នាទៅ-វិញទៅមក, រាជរដ្ឋាភិបាលបានដាក់ចេញនូវអាទិភាពជាយុទ្ធសាស្ត្រចំនួន ៥ ដែលអាទិភាពនីមួយៗមានវិធានការគន្លឹះជាក់លាក់ក្នុងការអនុវត្ត។ អាទិភាពជាយុទ្ធសាស្ត្រចំនួន ៥ រួមមាន៖

**ទី១-** ការពិនិត្យឡើងវិញ និង កែសម្រួលសេវានិងនីតិវិធីស្នើសុំ។

**ទី២-** ការអភិវឌ្ឍ និង បន្តធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ប្រព័ន្ធបច្ចេកវិទ្យា-ព័ត៌មានសម្រាប់ផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច។

**ទី៣-** ការរៀបចំ និង ធ្វើទំនើបកម្មទិន្នន័យគោលឱ្យមានគុណភាពក្នុងក្របខ័ណ្ឌធុរកិច្ច។

**ទី៤-** ការជំរុញការផ្សព្វផ្សាយព័ត៌មានអំពីសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច។

**ទី៥-** ការលើកកម្ពស់សមត្ថភាពមន្ត្រីផ្តល់សេវា និង ការរៀបចំយន្តការគាំទ្រអ្នកប្រើប្រាស់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច។

### ៣.៤.១- ការពិនិត្យឡើងវិញ និង កែសម្រួលសេវានិងនីតិវិធីស្នើសុំ

ការកសាងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច ទាមទារឱ្យមានកិច្ចសហការ និង អន្តរសេកម្ម រវាងក្រសួង ស្ថាប័នពាក់ព័ន្ធ សំដៅធ្វើការរួមគ្នាជាតួអង្គតែមួយ ដើម្បីធានាសង្គតិភាព គុណភាព និង ប្រសិទ្ធភាពនៃការផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច។ ដូច្នេះ, ក្នុងអាទិភាពជាយុទ្ធសាស្ត្រនេះ ក្រសួង ស្ថាប័ន ត្រូវផ្តល់កិច្ចសហការ ក្នុងការពិនិត្យកែសម្រួលនីតិវិធីការងារនៅក្នុងការផ្តល់សេវា និង ការកំណត់ យន្តការការងារក្នុងការរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច។

ការពិនិត្យឡើងវិញ និង កែលម្អនីតិវិធីការងារនៅក្នុងការផ្តល់សេវារបស់សេវាអាទិភាព មាន សារៈសំខាន់ក្នុងគោលដៅរក្សាតុល្យភាពរវាងតម្រូវការផ្នែកបទប្បញ្ញត្តិ និង ផលប្រយោជន៍របស់ធុរកិច្ច (Balance Between Regulatory Requirements and Business Interests)។ ដូចនេះ, ក្រសួង ស្ថាប័ន ត្រូវកាត់បន្ថយ ឬ លុបចេញនីតិវិធីមិនមានតម្លៃបន្ថែមខ្ពស់ ក្នុងដំណើរការនៃការស្នើសុំសេវា សម្រាប់ធុរកិច្ច ព្រមទាំងពិនិត្យឡើងវិញនូវអាជ្ញាបណ្ណ និង លិខិតអនុញ្ញាតទាំងអស់ ក្នុងវិស័យនីមួយៗ លើលទ្ធភាពក្នុងការលុបចេញ ឬ ផ្តុំបញ្ចូលគ្នានូវអាជ្ញាបណ្ណ និង លិខិតអនុញ្ញាតដែលមានលក្ខណៈ ប្រហាក់ប្រហែលគ្នា ដើម្បីបង្កភាពងាយស្រួលដល់ធុរជន ស្របតាមគោលការណ៍គាំទ្រធុរកិច្ចជាចម្បង។

ជាមួយគ្នានេះ, ក្រសួង ស្ថាប័ន ត្រូវចូលរួមរៀបចំបញ្ជីសេវាសម្រាប់ធុរកិច្ច (Service Catalog) ហើយធ្វើអាទិភាវូបនីយកម្មសេវាទាំងនោះ សម្រាប់បញ្ចូលជាសេវាអេឡិចត្រូនិក ដោយផ្តោតលើគោល-ការណ៍ចំនួន ៣ រួមមាន "តម្រូវការខ្ពស់, ភាពស្មុគស្មាញទាប និង កម្រិតហានិភ័យទាប" ឬ តាម ការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល។ កិច្ចការនេះ នឹងត្រូវអនុវត្តជាប្រចាំក្នុងការធ្វើបច្ចុប្បន្នភាព ដើម្បី ឆ្លុះបញ្ចាំងពីស្ថានភាពនៃការផ្តល់សេវាសម្រាប់ធុរកិច្ចនៅតាមក្រសួង ស្ថាប័ន។

### ៣.៤.២- ការអភិវឌ្ឍ និង បន្តធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច

អាទិភាពជាយុទ្ធសាស្ត្រនេះ ផ្តោតលើការរៀបចំ និង ពង្រឹងមធ្យោបាយឌីជីថល គាំទ្រដល់ ការផ្តល់សេវាពាក់ព័ន្ធធុរកិច្ច។ ក្រសួង ស្ថាប័នត្រូវធ្វើទំនើបកម្ម ឬ អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ផ្តល់សេវា តាមរយៈការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថលមានស្រាប់ ជាមួយ មុខងារតម្រូវការ និង មុខងារមិនតម្រូវការ អនុលោមតាមគោលការណ៍ណែនាំផ្នែកបច្ចេកទេស មានក្នុង ឧបសម្ព័ន្ធ ៣ នៃយុទ្ធសាស្ត្រនេះ។ ក្នុងន័យនេះ, ដើម្បីសម្រួលដល់ការធ្វើទំនើបកម្ម និង ការអភិវឌ្ឍ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដល់ក្រសួង ស្ថាប័នមួយចំនួន, ប្រព័ន្ធគំរូ (Basic System Template) នឹង ត្រូវបានអភិវឌ្ឍដើម្បីជាមូលដ្ឋានសម្រាប់ក្រសួង ស្ថាប័នយកទៅអភិវឌ្ឍ និង ប្រើប្រាស់បន្ត។ ប្រព័ន្ធគំរូ នេះ មានមុខងារមូលដ្ឋានសំខាន់ៗ ជាពិសេសទៅលើមុខងារមិនតម្រូវការ ដើម្បីធានាអន្តរប្រតិបត្តិការ ជាមួយប្រព័ន្ធដទៃទៀត និង ស្តង់ដាររួមក្នុងប្រព័ន្ធអេកូឡូស៊ីជារួម។

ជាការអនុវត្តការងារ, ក្រសួង ស្ថាប័នត្រូវប្រើប្រាស់ធនធានមានស្រាប់ឱ្យអស់ពីលទ្ធភាព ដើម្បី ធានាបានប្រសិទ្ធភាពនៃការវិនិយោគ។ ក្នុងករណីពុំមានធនធានបច្ចេកទេសគ្រប់គ្រាន់, ក្រសួង ស្ថាប័ន អាចពិនិត្យលទ្ធភាពប្រើប្រាស់សេវាកម្មរបស់វិស័យឯកជន ក្នុងការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ដោយត្រូវគោរពតាមគោលការណ៍ណែនាំផ្នែកបច្ចេកទេសឱ្យបានម៉ឺងម៉ាត់ និង ត្រូវជានាភាពជាម្ចាស់នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រួមទាំងការគ្រប់គ្រងទិន្នន័យផងដែរ។

រូបភាពទី៤: ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល




### ៣.៤.៣- ការរៀបចំ និង ធ្វើទំនើបកម្មទិន្នន័យគោលឱ្យមានគុណភាព ក្នុងក្របខ័ណ្ឌធុរកិច្ច

ដើម្បីជំរុញការកសាងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច និង លើកកម្ពស់អភិបាលកិច្ចទិន្នន័យ, ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់អាទិភាពដល់ការរៀបចំ និង ធ្វើទំនើបកម្មទិន្នន័យគោល (Base Registry) សំខាន់ៗប្រកបដោយគុណភាព និង គ្រប់ជ្រុងជ្រោយ ដែលគាំទ្រដល់ប្រតិបត្តិការរបស់ធុរកិច្ច រួមមាន ទិន្នន័យគោលអាជីវកម្ម ទិន្នន័យគោលរូបវន្តបុគ្គល និង ទិន្នន័យគោលទ្រព្យ-សម្បត្តិ។

ដូច្នេះ, អាទិភាពជាយុទ្ធសាស្ត្រនេះផ្តោតលើការរៀបចំ និង ធ្វើទំនើបកម្មទិន្នន័យគោលទាំង-នោះ ដោយក្រសួង ស្ថាប័នត្រូវគ្រប់គ្រងទិន្នន័យទាំងនោះឱ្យបានម៉ត់ចត់ ស្របតាមគោលការណ៍ណែនាំផ្នែកបច្ចេកទេស និង បទប្បញ្ញត្តិមានជាធរមាន។ ចំពោះប្រភេទទិន្នន័យគោលដែលមានលក្ខណៈរសើប, ក្រសួង ស្ថាប័ន ត្រូវជានាថាប្រព័ន្ធគ្រប់គ្រងទិន្នន័យគោលទាំងនោះ ត្រូវអភិវឌ្ឍ និង គ្រប់គ្រងដោយរដ្ឋ និង មិនអាចប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធក្លោដ ឬ មជ្ឈមណ្ឌលទិន្នន័យរបស់រដ្ឋបរទេសឡើយ ចៀសវាងការបែកធ្លាយទិន្នន័យរសើបទាំងនោះដោយថាហេតុ។ បន្ថែមលើនេះ, ក្រសួង ស្ថាប័នដែលជាបុគ្គលគ្រប់គ្រងទិន្នន័យគោលក្នុងក្របខ័ណ្ឌធុរកិច្ច ត្រូវជានាការបើកចំហ និង ចែករំលែកទិន្នន័យគោលក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច តាមរយៈថ្នាល CamDX ស្របតាមគោលការណ៍ណែនាំផ្នែកបច្ចេកទេស ក្នុងយុទ្ធសាស្ត្រនេះ ដើម្បីសម្រួលដល់ការបញ្ចូលទិន្នន័យ និង បង្កើនសុចរិតភាពនៃទិន្នន័យ ព្រមទាំងជំរុញការចូលរួមរបស់ធុរជន ក្នុងការធ្វើអន្តរប្រតិបត្តិការជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់រដ្ឋដែលបើកចំហ សម្រាប់ការធ្វើសហថាមពល និង ការសហការបង្កើតថ្មីផងដែរ។

រូបភាពទី៥: ទិន្នន័យគោលក្នុងក្របខ័ណ្ឌធុរកិច្ច




## ៣.៤.៤- ការជំរុញការផ្សព្វផ្សាយព័ត៌មានអំពីសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច

ការរៀបចំកន្លែងប្រមូលផ្តុំព័ត៌មានមួយកន្លែង (One-stop Shop) អំពីសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច មានសារៈសំខាន់ ដើម្បីផ្តល់ភាពងាយស្រួលដល់ធុរជនក្នុងការស្វែងរកព័ត៌មានពាក់ព័ន្ធសេវាគាំទ្រធុរកិច្ច ដើម្បីពិនិត្យ និង បំពេញអនុលោមភាពអាជីវកម្មរបស់ខ្លួន ប្រកបដោយតម្លាភាព។ ដូចនេះ, អាទិភាពជាយុទ្ធសាស្ត្រនេះ ផ្តោតសំខាន់លើការរៀបចំ និង ពង្រឹងយន្តការផ្សព្វផ្សាយព័ត៌មានអំពីសេវាអេឡិចត្រូនិកឱ្យបានទូលំទូលាយទៅដល់ធុរជន ឬ អ្នកប្រើប្រាស់ប្រព័ន្ធ តាមរយៈការពង្រីកមុខងាររបស់ថ្នាល business.gov.kh ដោយគិតគូរអំពីមុខងារគាំទ្រផ្សេងៗ ដើម្បីសម្រួលដល់ធុរជន និង អ្នកប្រើប្រាស់ ក្នុងការស្វែងរកព័ត៌មានពាក់ព័ន្ធនឹងសេវាសម្រាប់ធុរកិច្ច។ ជាមួយគ្នានេះ, សិក្ខាសាលាបញ្ជ្រាបការយល់ដឹង, ការបង្កើតឯកសារផ្សព្វផ្សាយសម្បូរបែប ច្រើនប្រភេទ និង ច្រើនទម្រង់ ព្រមទាំងការផ្សព្វផ្សាយតាមបណ្តាញសង្គមនានា នឹងត្រូវអនុវត្តក្នុងគោលបំណងផ្តល់ព័ត៌មានច្បាស់លាស់ និងត្រឹមត្រូវអំពីការផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចរបស់ក្រសួង ស្ថាប័ន។

## ៣.៤.៥- ការលើកកម្ពស់សមត្ថភាពមន្ត្រីផ្តល់សេវា និង ការរៀបចំយន្តការគាំទ្រអ្នកប្រើប្រាស់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច

អាទិភាពជាយុទ្ធសាស្ត្រនេះ ផ្តោតលើការកសាងសមត្ថភាពមន្ត្រីផ្តល់សេវាដែលជាអ្នកមានអន្តរសកម្មផ្ទាល់ជាមួយអ្នកស្នើសុំ និង ការពង្រឹងយន្តការផ្តល់ការគាំទ្រអ្នកប្រើប្រាស់ ស្របតាមគោលការណ៍ឧត្តមភាពនៃប្រតិបត្តិការ។ ក្នុងន័យនេះ, មន្ត្រីផ្តល់សេវា ត្រូវសម្របខ្លួន និង ទទួលយកនូវការបណ្តុះបណ្តាលពាក់ព័ន្ធផ្សេងៗ អំពីនីតិវិធីនៃការអនុវត្តយន្តការការងារថ្មី ដើម្បីធានាបាននូវការផ្តល់បទពិសោធល្អទៅដល់អ្នកស្នើសុំសេវាសម្រាប់ធុរកិច្ច។ ជាមួយគ្នានេះ, យន្តការគាំទ្រអ្នកប្រើប្រាស់តាមប្រព័ន្ធអេឡិចត្រូនិក នឹងត្រូវពង្រឹង និង ពង្រីកវិសាលភាព ក្នុងគោលបំណងតាមដានវឌ្ឍនភាព និងលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច ឱ្យស្របតាមស្មារតីនៃការទទួលខុសត្រូវក្នុងតួនាទី ភារកិច្ចផ្តល់សេវាសាធារណៈរបស់ក្រសួង ស្ថាប័ន។ បន្ថែមលើនេះ, ការផ្លាស់ប្តូរនីតិវិធីផ្តល់

សេវាពីបែបប្រពៃណីមកបែបឌីជីថលទាមទារឱ្យក្រសួង ស្ថាប័ន រៀបចំយន្តការប្រតិបត្តិការសម្រាប់មន្ត្រីផ្តល់សេវា ដោយរំលេចច្បាស់លាស់អំពីរបៀបនៃការផ្តល់សេវា និង កិច្ចគាំទ្រដល់អ្នកស្នើសុំ ដើម្បីជំរុញការសម្របខ្លួនរបស់មន្ត្រីនឹងបរិវត្តកម្មឌីជីថល និង បង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសម្រាប់ធុរកិច្ចជារួម។

រូបភាពទី៦: ក្របខ័ណ្ឌរួមនៃយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨



## ៤- យន្តការចាត់ចែងអនុវត្ត, តាមដាន និង វាយតម្លៃ

ការអនុវត្តយុទ្ធសាស្ត្រនេះ ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាពខ្ពស់ និង ទទួលបានជោគជ័យ ទាមទារឱ្យមានកិច្ចសហការយ៉ាងជិតស្និទ្ធ និង ការចូលរួមប្រកបដោយឆន្ទៈនយោបាយខ្ពស់ពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលជាអ្នកផ្តល់សេវាដោយផ្ទាល់។ ការសម្របសម្រួលអន្តរ-ស្ថាប័ន ត្រូវប្រើប្រាស់យន្តការស្ថាប័នដែលមានស្រាប់ស្របតាមអភិក្រម "**ពង្រឹងជាជាងពង្រីក**"។ ក្នុងន័យនេះ, **យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨** បានកំណត់យន្តការការងារក្នុងការចាត់ចែងអនុវត្ត និង ការតាមដានវាយតម្លៃដូចខាងក្រោម៖

### ៤.១- យន្តការចាត់ចែងអនុវត្ត

**ក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច** និង លេខាធិការដ្ឋានរបស់ខ្លួនត្រូវបន្តសម្របសម្រួលអនុវត្តការងារនេះដោយផ្ទាល់ ទាំងទិដ្ឋភាពរដ្ឋបាល, បច្ចេកទេស និង បទប្បញ្ញត្តិជាប្រចាំថ្ងៃ ដូចមានកំណត់ក្នុងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ២៤៧ សសរ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២៣។ លេខាធិការដ្ឋានក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ត្រូវរៀបចំទម្រង់ផែនការសកម្មភាពលម្អិត សម្រាប់ក្រសួង ស្ថាប័ន ប្រើប្រាស់ក្នុងការរៀបចំផែនការសកម្មភាពលម្អិតប្រចាំឆ្នាំរៀងខ្លួន។ ក្រោមការសម្របសម្រួលរបស់លេខាធិការដ្ឋាន, **ក្រសួង ស្ថាប័ន** ដឹកនាំ និង ចូលរួមអនុវត្តវិធានការគន្លឹះ ត្រូវរៀបចំផែនការសកម្មភាពលម្អិតប្រចាំឆ្នាំ ឱ្យបានរួចរាល់មុនឆ្នាំអនុវត្តនីមួយៗ ឱ្យមានសង្គតិភាពទៅនឹងវិធានការគន្លឹះ នៅក្នុងឧបសម្ព័ន្ធ ១ ស្របតាមក្របខ័ណ្ឌពេលវេលាដែលបានកំណត់។ ដោយឡែក, ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការសកម្មភាពលម្អិតសម្រាប់ការអនុវត្តក្នុងឆ្នាំដំបូង ឱ្យបានរួចរាល់យ៉ាងយូរត្រឹមត្រីមាសទី ១ ដើម្បីជានាការអនុវត្តយុទ្ធសាស្ត្រឱ្យបានទាន់ពេលកំណត់។

បន្ថែមលើនេះ, ក្នុងក្របខ័ណ្ឌនៃការរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច, **អគ្គលេខាធិការ-ដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ** ត្រូវសហការជាមួយលេខាធិការដ្ឋានក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ក្នុងការចូលរួមរៀបចំបញ្ជីសេវាសាធារណៈសម្រាប់ធុរកិច្ច និង ចូលរួមពិនិត្យកែសម្រួលនីតិវិធីការងាររបស់សេវាអាទិភាពពាក់ព័ន្ធនឹងធុរកិច្ច ដូចជាការពិនិត្យលទ្ធភាពក្នុងការផ្តុំ ឬ កាត់ចេញសេវាសាធារណៈសម្រាប់ធុរកិច្ចដែលមានលក្ខណៈប្រហាក់-ប្រហែលគ្នា ឬ មិនមានតម្លៃបន្ថែមខ្ពស់, ការកាត់បន្ថយកម្រៃសេវា និង ការកែសម្រួលក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធជាដើម។ ជាមួយគ្នានេះ, លើទិដ្ឋភាពបច្ចេកទេសនៃការធ្វើឌីជីថលូបនីយកម្មសេវាអាទិភាព, **អគ្គលេខាធិការដ្ឋានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល** ត្រូវសហការជាមួយលេខាធិការដ្ឋានក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច លើការចូលរួមសម្របសម្រួល និង គាំទ្រផ្នែកបច្ចេកទេស ព្រមទាំងចូលរួមលើការបណ្តុះបណ្តាលសមត្ថភាព និង ជំនាញពាក់ព័ន្ធដល់មន្ត្រីផ្តល់សេវានៅតាមក្រសួង ស្ថាប័ន លើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផងដែរ។

ដើម្បីគាំទ្រការអនុវត្តវិធានការគន្លឹះក្នុងយុទ្ធសាស្ត្រ, ក្រសួង ស្ថាប័ន អាចប្រើប្រាស់ថវិកាពីប្រភពផ្សេងៗដូចជាថវិកាជាតិ, យន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន, ដៃគូអភិវឌ្ឍ និង ប្រភពស្របច្បាប់ដទៃទៀត។

## ៤.២- យន្តការតាមដាន និង វាយតម្លៃ

ក្រសួង ស្ថាប័ន ដឹកនាំ និង អនុវត្ត ត្រូវរៀបចំរបាយការណ៍វឌ្ឍនភាពជាប្រចាំ (ត្រីមាស, ឆមាស និង ឆ្នាំ) ដោយរំលេចបន្ថែមពីបញ្ហាប្រឈម និង/ឬ សំណូមពរពាក់ព័ន្ធ មកលេខាធិការដ្ឋានក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ដើម្បីចាត់វិធានការដោះស្រាយបញ្ហាចំពោះមុខឱ្យបានទាន់ពេល និង ចៀសវាងការរាំងស្ទះការងារអនុវត្តយុទ្ធសាស្ត្រ។ លេខាធិការដ្ឋាន នឹងបូកសរុបរបាយការណ៍វឌ្ឍនភាពរបស់ក្រសួង ស្ថាប័ន ដើម្បីរាយការណ៍ជូនក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច។

ទន្ទឹមនេះ, **គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល (គ.ស.ធ.ឌ.)** នឹងដើរតួនាទីជាអង្គភាពត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តយុទ្ធសាស្ត្រនេះជារួម។ អគ្គលេខាធិការដ្ឋាន គ.ស.ធ.ឌ. ជាសេនាធិការ ត្រូវរៀបចំសូចនាករសមិទ្ធកម្មគន្លឹះ, យន្តការប្រមូលទិន្នន័យ និង របាយការណ៍វាយតម្លៃលើការអនុវត្តយុទ្ធសាស្ត្រប្រចាំឆ្នាំ ពីឆ្នាំ ២០២៥ ដល់ឆ្នាំ ២០២៨ ជូនប្រមុខរាជរដ្ឋាភិបាល និង ស្នើសុំគោលការណ៍ណែនាំតម្រង់ទិសតាមការចាំបាច់។

រូបភាពទី៧: យន្តការស្ថាប័ន



## ៥- ការគ្រប់គ្រងហានិភ័យ

ការអនុវត្តយុទ្ធសាស្ត្រនេះ ក៏ទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ ទៅលើការគិតគូរអំពីសក្តានុពលនៃហានិភ័យ (Potential Risks) ដែលអាចកើតឡើង និង អាចជាកត្តាបន្ទប់បង្អាក់ ឬ ធ្វើឱ្យរាំងស្ទះ។ ហានិភ័យទាំងនោះមានដូចជា៖

**ទី១- ភាពរឹងត្អឹងនៃដំណើរការកែសម្រួលបទប្បញ្ញត្តិ**: សេវាសាធារណៈសម្រាប់ធុរកិច្ចតាមវិស័យនីមួយៗ ត្រូវបានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តតាមកម្រិតផ្សេងគ្នា។ ការកែសម្រួលលិខិតបទដ្ឋានគតិយុត្តមួយចំនួន មានភាពរឹងត្អឹង ដែលអាចរាំងស្ទះដល់ដំណើរការអនុវត្តយុទ្ធសាស្ត្រជារួម។ ដូច្នេះ, ក្រសួង ស្ថាប័ន និង តួអង្គពាក់ព័ន្ធដទៃទៀត ត្រូវត្រៀមខ្លួនផ្តល់កិច្ចសហការឱ្យបានជិតស្និទ្ធប្រកបដោយភាពទន់ភ្លន់ និង ស្មារតីបុរេសកម្ម ក្នុងដំណើរការនៃការកែសម្រួលបទប្បញ្ញត្តិពាក់ព័ន្ធ។

**ទី២- ការផ្លាស់ប្តូរ និង ការសម្របទៅនឹងរបៀបធ្វើការថ្មី**: ការកែសម្រួលនីតិវិធីការងារផ្តល់សេវា នឹងនាំមកនូវការផ្លាស់ប្តូររបៀបធ្វើការថ្មី ក្នុងការផ្តល់សេវា ដែលអាចបង្កឱ្យមានបញ្ហាប្រឈមដល់មន្ត្រីប្រតិបត្តិនៅតាមក្រសួង ស្ថាប័នក្នុងការសម្របខ្លួនឱ្យបានក្នុងរយៈពេលខ្លី។ ក្នុងន័យនេះ ក្រសួង ស្ថាប័ន ត្រូវសហការជាមួយលេខាធិការដ្ឋានក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ដើម្បីរៀបចំ និង ពង្រឹងការអនុវត្តវិធាន និង នីតិវិធីប្រតិបត្តិស្តង់ដា (Standard Operation Procedure-SOP) ក្នុងការផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចប្រកបដោយប្រសិទ្ធភាពខ្ពស់។

**ទី៣- សមត្ថភាពក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថលតាមក្រសួង ស្ថាប័ន និង វិស័យឯកជន**: កម្រិតខុសគ្នាទៅលើសមត្ថភាពចាប់យក និង ប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនៅតាមក្រសួង ស្ថាប័ន អាចបង្កជាបញ្ហាប្រឈមក្នុងកាអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន អនុលោមតាមគោលការណ៍ណែនាំផ្នែកបច្ចេកទេស នៅក្នុងយុទ្ធសាស្ត្រនេះ។ ការណ៍នេះ នឹងអាចបង្កជាកត្តារាំងមួយដល់ក្រសួង ស្ថាប័នក្នុងការចូលរួមកសាងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច ស្របតាមអភិក្រម "**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**"។ ទន្ទឹមនេះ, ការចាប់យកបច្ចេកវិទ្យាឌីជីថលរបស់អ្នកស្នើសុំសេវាមួយចំនួនក្នុងវិស័យឯកជននៅមានកម្រិតនៅឡើយ ដែលអាចប៉ះពាល់ដល់ការពង្រីកវិសាលភាពការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា-ព័ត៌មាន សម្រាប់ផ្តល់សេវា។ ដូច្នេះ, ការបន្តអភិវឌ្ឍ និង ពង្រឹងសមត្ថភាពបច្ចេកទេសជាប្រចាំសម្រាប់ក្រសួង ស្ថាប័ន, ព្រមទាំងការលើកកម្ពស់សមត្ថភាពចាប់យកបច្ចេកវិទ្យាឌីជីថលរបស់អ្នកស្នើសុំ មានភាពចាំបាច់ ដើម្បីធានាបានការបង្កើត និង ទទួលបានបទពិសោធមួយល្អប្រសើរ ក្នុងការស្នើសុំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច។

## ៦- សេចក្ដីសន្និដ្ឋាន

ការបន្តកែទម្រង់ និង ធ្វើទំនើបកម្មសេវាសម្រាប់ធុរកិច្ច មានសារៈសំខាន់ក្នុងការជំរុញនវានុវត្តន៍នៃសេវាសាធារណៈ ក្នុងដំណើរឆ្ពោះទៅរកការកសាងបរិយាកាសធុរកិច្ចអំណោយផល។ ក្នុងន័យនេះ, **«យុទ្ធសាស្ត្រស្ដីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨»** របស់រាជរដ្ឋាភិបាល ជាផែនទីបង្ហាញផ្លូវយ៉ាងសំខាន់ ក៏ដូចជាក្របខ័ណ្ឌមួយច្បាស់លាស់ សម្រាប់ក្រសួង ស្ថាប័ន ក្នុងការរៀបចំ និង ផ្ដល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព គណនេយ្យភាព និង តម្លាភាព។ លើសពីនេះទៅទៀត, យុទ្ធសាស្ត្រនេះ បានឆ្លើយតបនឹងស្នូលនៃ **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»** របស់រាជរដ្ឋាភិបាលនីតិកាលទី ៧ សំដៅចូលរួមបង្កើត **រដ្ឋបាលសាធារណៈទំនើប ប្រកបដោយសមត្ថភាពខ្ពស់, ខ្លាំង, វៃឆ្លាត និង ស្អាតស្អំ** តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន, ការពង្រឹងសមត្ថភាពមន្ត្រីឱ្យខ្លាំង និង ការផ្ដល់សេវាសាធារណៈបានល្អ។

តាមរយៈការអនុវត្តយុទ្ធសាស្ត្រនេះ, **ប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច** ប្រកបដោយភាពរស់រវើក និង អន្តរសកម្មរវាងតួអង្គពាក់ព័ន្ធ នឹងត្រូវបង្កើតឡើង ផ្អែកលើអភិក្រម "**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**"។ អន្តរសកម្មរវាងតួអង្គទាំងនេះនៅក្នុងប្រព័ន្ធអេកូឡូស៊ី បង្ហាញពីភាពប្រទាក់ក្រឡានៃការងារផ្ដល់សេវាគាំទ្រធុរកិច្ច ដែលទាមទារឱ្យមានការសហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីសម្រួល និង គាំទ្រធុរជនក្នុងការបំពេញអនុលោមភាពអាជីវកម្មឱ្យបានពេញលេញ។ ក្នុងន័យនេះ, យុទ្ធសាស្ត្រ បានផ្ដោតសំខាន់លើការពិនិត្យឡើងវិញ និង កែសម្រួល ឬ លុបចេញនីតិវិធីការងារក្នុងការស្នើសុំសេវា ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ឬ មិនមានតម្លៃបន្ថែមខ្ពស់ និង ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានអន្តរប្រតិបត្តិការ ហើយអាចផ្លាស់ប្ដូរទិន្នន័យរវាងគ្នា ដែលធានាបានប្រសិទ្ធភាពនៃការវិនិយោគ ព្រមទាំងការពង្រឹងយន្តការផ្សព្វផ្សាយ និង ការកសាងសមត្ថភាពមន្ត្រីផ្ដល់សេវា សំដៅបង្កើតបទពិសោធល្អនៃការផ្ដល់សេវាសាធារណៈគាំទ្រធុរកិច្ចដល់អ្នកស្នើសុំផងដែរ ដើម្បីឈានទៅរកការរៀបចំឱ្យបាន "**សេវាអេឡិចត្រូនិកគំរូសម្រាប់ធុរកិច្ច**"។ បន្ថែមលើនេះ, ការកសាងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ចរឹងមាំ នឹងក្លាយជាមូលដ្ឋានសំខាន់ក្នុងការរៀបចំឃ្លាំងទុកដាក់ទិន្នន័យវិស័យធុរកិច្ច អាចជំរុញនវានុវត្តន៍ក្នុងការផ្ដល់សេវាសាធារណៈ ដែលជាកាតាលីករយ៉ាងសំខាន់ ក្នុងការចូលរួមអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាឱ្យកាន់តែមានភាពរស់រវើក និង ប្រកបដោយភាពធន់។

# ឧបសម្ព័ន្ធ ១- តារាងវិធានការគន្លឹះនៃយុទ្ធសាស្ត្រ

| ល.រ. | វិធានការគន្លឹះ | ក្រសួង ស្ថាប័នទទួលបន្ទុក | ក្របខ័ណ្ឌពេលវេលា |
|---|---|---|---|
| I. ការពិនិត្យឡើងវិញ និង កែសម្រួលសេវានិងនីតិវិធីស្នើសុំ | | | |
| ១. | រៀបចំ ចងក្រង និង ធ្វើបច្ចុប្បន្នកម្មបញ្ជីសេវាសម្រាប់ធុរកិច្ចទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ | - គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ<br>- លេខាធិការដ្ឋាន<br>- ក្រសួង ស្ថាប័នផ្តល់សេវា | ២០២៥-២០២៨ (ធ្វើជាប្រចាំ) |
| ២. | កែសម្រួលនីតិវិធីការងារក្នុងការស្នើសុំសេវា, លុបចេញ ឬ ផ្គួបចូលគ្នានូវសេវាសម្រាប់ធុរកិច្ច ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ឬ មិនមានតម្លៃបន្ថែមខ្ពស់ និង កាត់បន្ថយកម្រៃសេវានីមួយៗ តាមរយៈការកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ផ្អែកតាមគោលការណ៍គាំទ្រធុរកិច្ចជាចម្បង (Pro-business Principle) | - គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល<br>- គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ<br>- គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល<br>- ក្រសួង ស្ថាប័នផ្តល់សេវា<br>- លេខាធិការដ្ឋាន | ២០២៥-២០២៨ (ធ្វើជាប្រចាំ) |
| ៣. | ធ្វើអាទិភាវូបនីយកម្មសេវាសម្រាប់ធុរកិច្ច ដើម្បីរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ជាដំណាក់កាល ដោយផ្អែកលើគោលការណ៍ "តម្រូវការខ្ពស់, ភាពស្មុគស្មាញទាប និង កម្រិតហានិភ័យទាប" និង ធនធានរបស់ក្រសួង ស្ថាប័នផ្តល់សេវា | - ក្រសួង ស្ថាប័នផ្តល់សេវា<br>- លេខាធិការដ្ឋាន<br>- គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ | ២០២៥-២០២៦ |

| | | | |
|---|---|---|---|
| ៤. | រៀបចំវិធាន និង នីតិវិធីក្នុងការរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ដែលបញ្ជាក់ពីលក្ខខណ្ឌតម្រូវ និង កាតព្វកិច្ចរបស់ក្រសួង ស្ថាប័នផ្តល់សេវា | - លេខាធិការដ្ឋាន<br>- ក្រសួង ស្ថាប័នផ្តល់សេវា | ២០២៥-២០២៦ |
| II. **ការអភិវឌ្ឍ និង បន្តធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច** | | | |
| ១. | រៀបចំគំរូប្រព័ន្ធ (Generic Template) សម្រាប់ក្រសួង ស្ថាប័នដែលចូលរួមក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច ដើម្បីធានាបាននូវស្តង់ដាររួម និង អន្តរ-ប្រតិបត្តិការក្នុងការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង ហេដ្ឋារចនាសម្ព័ន្ធឌីជីថល | លេខាធិការដ្ឋាន | ២០២៥-២០២៦ |
| ២. | រៀបចំប្រព័ន្ធតាមដានស្ថានភាព (Heartbeat Health Check System) សម្រាប់តាមដានប្រព័ន្ធរបស់ក្រសួង ស្ថាប័ន និង អាចធ្វើសន្ទានកម្មជាមួយប្រព័ន្ធផ្តល់ដំណឹង (Notification System) ដូចជា តេឡេក្រាម ឬ អ៊ីម៉ែលជាដើម | - លេខាធិការដ្ឋាន<br>- ក្រសួង ស្ថាប័នផ្តល់សេវា | ២០២៥-២០២៦ |
| ៣. | ធ្វើទំនើបកម្ម និង/ឬ អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលគាំទ្រការផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ដោយអនុលោមតាមគោលការណ៍ណែនាំផ្នែកបច្ចេកទេស | - ក្រសួង ស្ថាប័នផ្តល់សេវា<br>- គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល<br>- លេខាធិការដ្ឋាន | ២០២៥-២០២៨ (ធ្វើជាប្រចាំ) |
| ៤. | រៀបចំធ្វើសមាហរណកម្ម ឬ សន្ទានកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង ស្ថាប័នដែលត្រូវផ្លាស់ប្តូរទិន្នន័យតាមថ្នាល CamDX | - លេខាធិការដ្ឋាន<br>- ក្រសួង ស្ថាប័នផ្តល់សេវា | ២០២៥-២០២៨ (ធ្វើជាប្រចាំ) |
| ៥. | ពង្រឹងសមាសធាតុស្នូលនៃថ្នាលឌីជីថលគ្រឹះ CamDX, CamDigiKey និង Digital Signature ដើម្បីបង្កើនសុវត្ថិភាព, ប្រសិទ្ធភាព និង ទំហំប្រតិបត្តិការសម្រាប់ការផ្លាស់ប្តូរទិន្នន័យក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច | លេខាធិការដ្ឋាន | ២០២៥-២០២៨ (ធ្វើជាប្រចាំ) |
| ៦. | ពង្រីកវិសាលភាពការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថលទាំង ៤ (CamDX, CamDigiKey, Bakong, verify.gov.kh) ក្នុងការកសាង និង អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលគាំទ្រដល់ការផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច | - លេខាធិការដ្ឋាន<br>- គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល<br>- ក្រសួង ស្ថាប័នផ្តល់សេវា | ២០២៥-២០២៨ (ធ្វើជាប្រចាំ) |

| | | | |
|---|---|---|---|
| III. **ការរៀបចំ និង ធ្វើទំនើបកម្មទិន្នន័យគោលឱ្យមានគុណភាព ក្នុងក្របខ័ណ្ឌធុរកិច្ច** | | | |
| ១. | រៀបចំ ឬ ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យគោលសំខាន់ៗនៅតាមក្រសួង ស្ថាប័ន | - ក្រសួង ស្ថាប័នផ្តល់សេវា<br>- លេខាធិការដ្ឋាន | ២០២៥-២០២៨<br>(ធ្វើជាប្រចាំ) |
| ២. | បើកចំហទិន្នន័យគោល សម្រាប់ការផ្ទៀងផ្ទាត់ និង ផ្លាស់ប្តូរទិន្នន័យរវាងក្រសួង ស្ថាប័នពាក់ព័ន្ធនៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច តាមរយៈថ្នាល CamDX | - ក្រសួង ស្ថាប័នផ្តល់សេវា<br>- លេខាធិការដ្ឋាន | ២០២៦-២០២៨ |
| IV. **ការជំរុញការផ្សព្វផ្សាយព័ត៌មានអំពីសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច** | | | |
| ១. | ពង្រឹកមុខងាររបស់ថ្នាល business.gov.kh ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ធុរកិច្ច | លេខាធិការដ្ឋាន | ២០២៥-២០២៧ |
| ២. | ផលិតឯកសារ និង/ឬ មាតិកាណែនាំអំពីសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច រួមមាន សៀវភៅមគ្គុទ្ទេសក៍, វីដេអូ, ផ្ទាំងផ្សព្វផ្សាយ (Poster) សម្រាប់សាធារណជនទូទៅ ព្រមទាំងផ្សព្វផ្សាយឱ្យបានទូលំទូលាយតាមប្រព័ន្ធផ្សព្វផ្សាយគ្រប់ប្រភេទ | - ក្រសួង ស្ថាប័នផ្តល់សេវា<br>- លេខាធិការដ្ឋាន | ២០២៥-២០២៨<br>(ធ្វើជាប្រចាំ) |
| ៣. | ផ្សព្វផ្សាយ និង ជំរុញការប្រើប្រាស់ថ្នាលបណ្តុំព័ត៌មានធុរកិច្ច business.gov.kh | - លេខាធិការដ្ឋាន<br>- ក្រសួង ស្ថាប័នផ្តល់សេវា | ២០២៥-២០២៨<br>(ធ្វើជាប្រចាំ) |
| ៤. | រៀបចំសិក្ខាសាលាផ្សព្វផ្សាយហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថលរបស់កម្ពុជា | - លេខាធិការដ្ឋាន<br>- គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ២០២៥-២០២៨<br>(មួយឆ្នាំម្តង) |
| ៥. | រៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល និង/ឬ ពិព័រណ៍អំពីអត្ថប្រយោជន៍ និង នីតិវិធីស្នើសុំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ដើម្បីលើកកម្ពស់ការយល់ដឹង បង្កើនទំនុកចិត្ត និង ជំរុញការគាំទ្ររបស់សាធារណជន ចំពោះសេវាអេឡិចត្រូនិក សម្រាប់ធុរកិច្ច | - ក្រសួង ស្ថាប័នផ្តល់សេវា<br>- គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ<br>- គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល<br>- លេខាធិការដ្ឋាន | ២០២៥-២០២៨<br>(មួយឆ្នាំម្តង) |

| | | | |
|---|---|---|---|
| V.**ការលើកកម្ពស់សមត្ថភាពមន្ត្រីផ្តល់សេវា និង ការរៀបចំយន្តការគាំទ្រអ្នកប្រើប្រាស់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច** | | | |
| ១. | រៀបចំផែនការអភិវឌ្ឍសមត្ថភាពមន្ត្រីប្រតិបត្តិទទួលបន្ទុកផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច និង ផ្តល់កិច្ចគាំទ្រអ្នកស្នើសុំសេវា ដើម្បីពង្រឹងសមត្ថភាពក្នុងការសម្របខ្លួននឹងនីតិវិធីការងារថ្មី និង ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | - ក្រសួង ស្ថាប័នផ្តល់សេវា<br>- គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ<br>- លេខាធិការដ្ឋាន | ២០២៥-២០២៦ |
| ២. | រៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីផ្តល់សេវាសម្រាប់ធុរកិច្ចជាប្រចាំ | - លេខាធិការដ្ឋាន<br>- គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល<br>- ក្រសួង ស្ថាប័នផ្តល់សេវា | ២០២៦-២០២៨ (ធ្វើជាប្រចាំ) |
| ៣. | រៀបចំយន្តការប្រតិបត្តិការលម្អិតអំពីរបៀបពិនិត្យពាក្យស្នើសុំ និង ផ្តល់កិច្ចគាំទ្រដល់អ្នកស្នើសុំសេវាតាមមធ្យោបាយផ្សេងៗ | - ក្រសួង ស្ថាប័នផ្តល់សេវា<br>- លេខាធិការដ្ឋាន | ២០២៥-២០២៧ |
| ៤. | ពង្រឹង និង ពង្រីកវិសាលភាពប្រព័ន្ធសម្រាប់ផ្តល់យន្តការគាំទ្រ សម្រាប់ក្រុមការងារគាំទ្រកណ្តាល និង ក្រុមការងារគាំទ្ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ | - លេខាធិការដ្ឋាន<br>- ក្រសួង ស្ថាប័នផ្តល់សេវា | ២០២៦-២០២៧ |

# ឧបសម្ព័ន្ធ ២- សទ្ទានុក្រម

| ល.រ | ភាសាខ្មែរ | ភាសាអង់គ្លេស | និយមន័យ |
|---|---|---|---|
| ១. | កូដនីយកម្ម | Encryption | ការបំប្លែងព័ត៌មាន ឬទិន្នន័យទៅជាកូដពិសេសណាមួយដែលគេមិនអាចយល់ ឬប្រើប្រាស់បាន តាមរយៈវិធីសាស្ត្រ Algorithm ណាមួយ។ ដើម្បីបំប្លែងព័ត៌មាននោះមកជាទម្រង់ដើមវិញ (Decryption) គឺតម្រូវឱ្យប្រើប្រាស់លេខកូនសោរសម្ងាត់ (Secret Key)។ |
| ២. | ឌីជីថលូបនីយកម្ម | Digitalization | ដំណើរការនៃការកែសម្រួលការធ្វើអភិបាលកិច្ច ឬ ធុរកិច្ច ឬ ដំណើរការសកម្មភាពអ្វីមួយ ឱ្យមានប្រសិទ្ធភាព តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ |
| ៣. | ថ្នាលផ្ទៀងផ្ទាត់ឯកសារ | verify.gov.kh | ថ្នាលបច្ចេកវិទ្យារបស់រាជរដ្ឋាភិបាល ដែលអភិវឌ្ឍដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សម្រាប់ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារ ដែលមានដាក់បញ្ចូលឃ្យូ.អ.កូដ. ស្តង់ដា។ |
| ៤. | ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា | Cambodia Data Exchange (CamDX) | ថ្នាលបច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាល សម្រាប់ផ្លាស់ប្តូរទិន្នន័យដោយប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកំព្យូទ័រ រវាងប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មានរបស់ក្រសួង ស្ថាប័ននានា និងរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់វិស័យឯកជន ដោយសុវត្ថិភាព និង ដោយយន្តការច្បាស់លាស់ តាមរយៈប្រព័ន្ធអ៊ីនធឺណិត ឬ បណ្តាញតភ្ជាប់ឌីជីថលផ្សេងៗ។ |
| ៥. | ថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា | Cambodia Digital Key (CamDigiKey) | ប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលរបស់រាជរដ្ឋាភិបាល សម្រាប់បង្កើត និង ធ្វើយថាភូតកម្មរបស់អតិថិជនក្នុងពិភពឌីជីថលតាមប្រព័ន្ធអេឡិចត្រូនិក ដោយពឹងផ្អែកលើឯកសារសម្គាល់អត្តសញ្ញាណដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល។ |
| ៦. | ទិន្នន័យគោល | Base Registry | ប្រភពទិន្នន័យមូលដ្ឋានដែលអាចទុកចិត្តបានមានជាអាទិ៍៖ ទិន្នន័យបុគ្គល, ក្រុមហ៊ុន, យានយន្ត, អាជ្ញាបណ្ណ, អាគារ, ទីតាំង និងផ្លូវ ដែលទទួលបន្ទុកដោយក្រសួង ស្ថាប័ន |

| | | | |
|---|---|---|---|
| | | | ក្នុងការប្រមូល ប្រើប្រាស់ ធ្វើបច្ចុប្បន្នភាព និងរក្សាទុក ព្រមទាំងអាចចែករំលែក និង ប្រើប្រាស់ឡើងវិញបាន ដោយតួអង្គពាក់ព័ន្ធផ្សេងទៀត។ |
| ៧. | ប្រព័ន្ធអេកូឡូស៊ីឌីជីថល | Digital Ecosystem | បណ្ដាញប្រទាក់ក្រឡានៃអន្តរសកម្មរវាងមនុស្ស ឬ ស្ថាប័ន, ធុរកិច្ច, ប្រព័ន្ធ ឬ កម្មវិធី និងទិន្នន័យ ដែលប្រើប្រាស់បច្ចេកវិទ្យា ដែលអន្តរសកម្មទាំងនោះ មានភាពបត់បែន ភាពប្រទាក់ក្រឡាគ្នាទៅវិញទៅមក និង អាចសម្របនឹងការវិវត្តនៃបច្ចេកវិទ្យា និង តម្រូវការរបស់អ្នកប្រើប្រាស់។ |
| ៨. | ប្រព័ន្ធបាគង | Bakong | ប្រព័ន្ធទូទាត់សងប្រាក់កន្លោង បង្កើតឡើងដោយធនាគារជាតិនៃកម្ពុជា ក្នុងគោល-បំណងផ្ដល់លទ្ធភាពទូទាត់ឆ្លងគ្រឹះស្ថាន, បង្កើនប្រសិទ្ធភាពប្រតិបត្តិការទូទាត់, ជំរុញបរិយាបន្នហិរញ្ញវត្ថុ និង លើកកម្ពស់ទូទាត់ជាប្រាក់រៀល។ |
| ៩. | បំប្លែងទិន្នន័យឯកទិស | Hashing | វិធីសាស្ត្រក្នុងការបំប្លែងតួអក្សរ (String of Text) ទៅជាបណ្ដុំលេខ និងតួអក្សរដែលមានប្រវែងជាក់លាក់មួយ។ ការបំប្លែងនេះមានទម្រង់មួយដែលពិសេស ហើយមិនអាចត្រូវបានបំប្លែងមកដូចដើមវិញទេ (One-way Function, Irreversible)។ |
| ១០. | ផតថល | Portal | គេហទំព័រប្រមូលផ្ដុំ និង សំយោគព័ត៌មានពីច្រើនប្រភព ដែលត្រូវបានរៀបចំឡើងក្នុងគោល-បំណងជាក់លាក់មួយ និង ផ្ដល់លទ្ធភាពតភ្ជាប់ទៅកាន់គេហទំព័រផ្ដល់សេវានានា។ |
| ១១. | មុខងារតម្រូវការ | Functional Requirement | បញ្ជីមុខងារដែលក្រសួង ស្ថាប័ន ផ្ដល់ឱ្យសម្រាប់អ្នកអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទៅតាមនីតិវិធីសម្រាប់ផ្ដល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ក្នុងសមត្ថកិច្ចរបស់ខ្លួន។ |
| ១២. | មុខងារមិនតម្រូវការ | Non-functional Requirement | មុខងារមិនចាំបាច់សម្រាប់ផ្ដល់សេវា ប៉ុន្តែត្រូវបានប្រើប្រាស់សម្រាប់បំពេញបន្ថែម ដើម្បីឱ្យប្រព័ន្ធមានលក្ខណៈទំនើប, មានសុវត្ថិភាព និង អាចធ្វើសន្ទានកម្មជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដទៃទៀត ក្នុងប្រព័ន្ធអេកូឡូស៊ី។ |

| | | | |
|---|---|---|---|
| ១៣. | សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ (អេភីអាយ) | Application Programming Interface (API) | ច្រកចេញ-ចូលនៃទំនាក់ទំនងក្នុងការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាពីរ ឬ ច្រើន។ |
| ១៤. | ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល | Digital Public Infrastructure (DPI) | ហេដ្ឋារចនាសម្ព័ន្ធឌីជីថលរួម (Shared Digital Infrastructure) បង្កើតឡើងក្នុងគោលបំណងគាំទ្រការផ្តល់សេវាសាធារណៈតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងៗ ដល់ប្រជាជន និង ធុរកិច្ច ប្រកបដោយសុវត្ថិភាព និង ស័ក្តិសិទ្ធភាព។ |
| ១៥. | អន្តរប្រតិបត្តិការ | Interoperability | សមត្ថភាពនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលអាចធ្វើសន្ទានកម្មជាមួយគ្នាក្នុងការផ្លាស់ប្តូរ និង ការប្រើប្រាស់ទិន្នន័យ ដែលជាទូទៅកើតឡើងដោយស្វ័យប្រវត្តិក្រោមលក្ខខណ្ឌច្បាស់លាស់។ |
| ១៦. | អភិបាលកិច្ចទិន្នន័យ | Data Governance | ការកំណត់ពីតួនាទី, សិទ្ធអំណាច, ដំណើរការ, ការគ្រប់គ្រង និង ការសម្រេចចិត្តរួមគ្នា ដើម្បីធ្វើការប្រមូល, រៀបចំ, រក្សាទុក, ចែករំលែក និង ប្រើប្រាស់ទិន្នន័យឱ្យបានត្រឹមត្រូវ។ |

## ឧបសម្ព័ន្ធ ៣- គោលការណ៍ណែនាំផ្នែកបច្ចេកទេស

### ផ្នែកទី ១ ៖ ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល

១- ការអភិវឌ្ឍប្រព័ន្ធផ្តល់សេវាអេឡិចត្រូនិកត្រូវប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល ឬ ថ្នាលឌីជីថលគ្រឹះទាំង ៤ រួមមាន CamDX, CamDigiKey, Bakong និង verify.gov.kh ដើម្បីធានានូវការកសាងប្រព័ន្ធជាប្រព័ន្ធអេកូឡូស៊ី។

- ប្រព័ន្ធផ្តល់សេវាអេឡិចត្រូនិកត្រូវប្រើប្រាស់ថ្នាល CamDX សម្រាប់ផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលជាសមាជិកដើម្បីទាញយក និង ផ្ទៀងផ្ទាត់ទិន្នន័យ។
- ប្រព័ន្ធផ្តល់សេវាអេឡិចត្រូនិកត្រូវប្រើប្រាស់ថ្នាល CamDigiKey សម្រាប់ចូលប្រើប្រាស់ប្រព័ន្ធផ្តល់សេវាអេឡិចត្រូនិកទាំងប្រព័ន្ធផ្នែកខាងមុខ (front-end) និង ផ្នែកខាងក្រោយ (back-office) ដោយមិនចាំបាច់តម្រូវឱ្យមានការបង្កើតគណនីដាច់ដោយឡែក។
- មុខងារទូទាត់ក្នុងប្រព័ន្ធផ្តល់សេវាអេឡិចត្រូនិកត្រូវប្រើប្រាស់ច្រកទូទាត់សងប្រាក់ (payment gateway) ដែលជាសមាជិក Bakong យ៉ាងហោចណាស់មួយ ដើម្បីផ្តល់លទ្ធភាពទូទាត់តាមស្តង់ដាឃ្យូអរ (KHQR code) ពីបណ្តាគ្រឹះស្ថានហិរញ្ញវត្ថុដែលជាសមាជិក Bakong។
- អាជ្ញាបណ្ណ លិខិតអនុញ្ញាត និង វិញ្ញាបនបត្រសម្គាល់នៃការទទួលបានការអនុញ្ញាតឱ្យប្រកបអាជីវកម្មលើសេវាណាមួយ ត្រូវមានស្តង់ដាឃ្យូអរ សម្រាប់ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារទាំងនេះដែលចេញដោយថ្នាល verify.gov.kh។

### ផ្នែកទី ២ ៖ ទិន្នន័យ និង អភិបាលកិច្ចទិន្នន័យនៃសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច

២- ដើម្បីរៀបចំប្រព័ន្ធផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច, ការធ្វើចំណាត់ថ្នាក់ទិន្នន័យមានសារៈសំខាន់។ ទិន្នន័យពីសេវាសាធារណៈសម្រាប់ធុរកិច្ច អាចមានដូចជា៖

- ទិន្នន័យដែលបង្កើតបានជាពាក្យស្នើសុំ ដែលជាបណ្តុំនៃទិន្នន័យអត្តសញ្ញាណសហគ្រាស, ទិន្នន័យអត្តសញ្ញាណបុគ្គលជាម្ចាស់សហគ្រាស, ទិន្នន័យអត្តសញ្ញាណអ្នកតំណាង, ទិន្នន័យសម្រាប់ត្រួតពិនិត្យក្នុងការអនុម័តផ្តល់សេវា, និង ទិន្នន័យពីឯកសារភ្ជាប់។
- ទិន្នន័យដែលកើតពីប្រព្រឹត្តកម្មពីមន្ត្រីត្រួតពិនិត្យ មានដូចជា ទិន្នន័យពីស្ថានភាពនៃការត្រួតពិនិត្យសេវា, ទិន្នន័យប្រវត្តិនៃការត្រួតពិនិត្យសេវា និង ទិន្នន័យលើអាជ្ញាបណ្ណ លិខិតអនុញ្ញាត និង វិញ្ញាបនបត្រ។
- ទិន្នន័យពីមន្ត្រីត្រួតពិនិត្យសេវា មានដូចជាទិន្នន័យអត្តសញ្ញាណមន្ត្រី និង ទិន្នន័យប្រព្រឹត្តកម្មរវាងមន្ត្រី និង ការផ្តល់សេវា។
- ទិន្នន័យដែលកើតពីប្រព្រឹត្តកម្មពីអ្នកស្នើសុំសេវា មានដូចជា ទិន្នន័យអត្តសញ្ញាណអ្នកស្នើសុំ, ទិន្នន័យទូទាត់កម្រៃសេវា និង ទិន្នន័យបញ្ជាក់ពីការយល់ព្រមចែករំលែកទិន្នន័យ។
- ទិន្នន័យរណបស្តង់ដា មានដូចជា ទិន្នន័យទីតាំង (រាជធានី/ខេត្ត, ក្រុង/ស្រុក/ខណ្ឌ, ឃុំ/សង្កាត់), ទិន្នន័យលេខកូដសកម្មភាពអាជីវកម្ម។ល។

៣- អភិបាលកិច្ចទិន្នន័យ កំណត់ពីរបៀបរបបនៃការផ្ដល់, ការកត់ត្រា, ការគ្រប់គ្រង, ការធ្វើប្រព្រឹត្តកម្មទិន្នន័យ ក្នុងក្របខ័ណ្ឌនៃការផ្ដល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច។

៤- ភាគីពាក់ព័ន្ធនឹងអភិបាលកិច្ចទិន្នន័យ រួមមាន៖

- ប្រធានទិន្នន័យ សំដៅអ្នកទទួលខុសត្រូវលើខ្លឹមសារ, អត្ថន័យ និងគុណភាពទិន្នន័យ ព្រមទាំងផ្ដល់ការយល់ព្រមលើការចែករំលែកទិន្នន័យ ទៅដល់បុគ្គលផ្សេងទៀត ក្នុងគោលបំណងណាមួយ។
- បុគ្គលគ្រប់គ្រងទិន្នន័យ សំដៅដល់រូបវន្តបុគ្គល នីតិបុគ្គលឯកជន គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬ សហគ្រាសសាធារណៈ ដែលកំណត់គោលបំណង និងមធ្យោបាយនៃការប្រមូល ការប្រើ-ប្រាស់ ឬ ការលាតត្រដាងទិន្នន័យ។
- បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ សំដៅដល់រូបវន្តបុគ្គល នីតិបុគ្គលឯកជន គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬ សហគ្រាសសាធារណៈដែលធ្វើប្រព្រឹត្តកម្មទិន្នន័យរបស់ប្រធានទិន្នន័យក្នុងនាមបុគ្គលគ្រប់គ្រងទិន្នន័យ ឬអាជ្ញាធរសាធារណៈ។
- បុគ្គលអភិបាលកិច្ចទិន្នន័យ សំដៅដល់រូបវន្តបុគ្គល នីតិបុគ្គលឯកជន គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬ សហគ្រាសសាធារណៈដែលតាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការអនុវត្តក្របខ័ណ្ឌអភិបាលកិច្ចទិន្នន័យដែលបានព្រមព្រៀង។

៥- ក្នុងក្របខ័ណ្ឌនៃការផ្ដល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច, ប្រធានទិន្នន័យ គឺជាអ្នកស្នើសុំសេវាដែលត្រូវផ្ដល់ទិន្នន័យរបស់ខ្លួន និង លក្ខខណ្ឌនៃការចែករំលែក ឬលាតត្រដាងទិន្នន័យរបស់ខ្លួនទៅកាន់បុគ្គលដទៃទៀត។ បុគ្គលគ្រប់គ្រងទិន្នន័យ គឺជាក្រសួង ស្ថាប័នដែលគ្រប់គ្រងប្រព័ន្ធផ្ដល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច។ ប្រព័ន្ធផ្ដល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចរបស់ក្រសួង ស្ថាប័ន ជាមធ្យោបាយកត់ត្រា ប្រមូល ប្រើប្រាស់ ប្រព្រឹត្តកម្ម និង លាតត្រដាងទិន្នន័យរបស់ប្រធានទិន្នន័យ តាមលក្ខខណ្ឌ និង ការយល់ព្រមពីប្រធានទិន្នន័យ។ បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ គឺជាក្រសួង ស្ថាប័ន ឬលេខាធិការដ្ឋាន ដែលប្រើប្រាស់ទិន្នន័យរបស់ប្រធានទិន្នន័យ ដែលត្រូវបានកត់ត្រាក្នុងប្រព័ន្ធសេវាអេឡិចត្រូនិកណាមួយ ក្នុងប្រព័ន្ធផ្ដល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចរបស់ខ្លួន សំដៅសម្រួលដល់ការបញ្ចូលទិន្នន័យ និង ផ្ទៀង-ផ្ទាត់ភាពត្រឹមត្រូវនៃទិន្នន័យ។

៦- ប្រគល់ភារកិច្ចដល់ប្រតិបត្តិករថ្នាល CamDX ជាបុគ្គលអភិបាលកិច្ចទិន្នន័យ ដោយឈរលើមូលដ្ឋានប្រព័ន្ធផ្ដល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចដែលមានតម្រូវការផ្លាស់ប្ដូរទិន្នន័យ ត្រូវធ្វើប្រតិបត្តិការផ្លាស់ប្ដូរទិន្នន័យតាមថ្នាល CamDX។

៧- មុនពេលកត់ត្រាទិន្នន័យរបស់ប្រធានទិន្នន័យ ក្នុងដំណាក់កាលស្នើសុំសេវា, ប្រព័ន្ធសេវាអេឡិចត្រូនិក ត្រូវមានយន្តការយល់ព្រមលើការចែករំលែកទិន្នន័យ ក្នុងចង្កោមប្រព័ន្ធផ្ដល់សេវាអេឡិចត្រូនិកដែលធ្វើប្រតិបត្តិការលើថ្នាល CamDX។ ការធ្វើបែបនេះ គឺដើម្បីឱ្យប្រធាន

ទិន្នន័យ បានផ្តល់ការយល់ព្រមជាមុន មុននឹងទិន្នន័យរបស់ខ្លួនត្រូវបានកត់ត្រា, ចែករំលែក និង ប្រើប្រាស់ ដោយស្វ័យប្រវត្តិក្នុងចង្កោមសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច។ បុគ្គលអភិបាលកិច្ចទិន្នន័យ ត្រូវត្រួតពិនិត្យ និង អាចបញ្ជាក់បានថា ទិន្នន័យរបស់ប្រធានទិន្នន័យ មិនត្រូវបានយកទៅប្រើប្រាស់ ខុសពីគោលបំណងបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាអេឡិចត្រូនិក។ ការចែករំលែកទិន្នន័យរបស់ប្រធានទិន្នន័យក្រៅពីចង្កោមប្រព័ន្ធផ្តល់សេវាអេឡិចត្រូនិក អាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីប្រធានទិន្នន័យ។

## ផ្នែកទី ៣ ៖ ការអភិវឌ្ឍប្រព័ន្ធផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច

### ៣.១- ការកំណត់មុខងារនៃប្រព័ន្ធផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច

៨- ប្រព័ន្ធផ្តល់សេវាអេឡិចត្រូនិកមានពីរផ្នែក គឺ ផ្នែកខាងមុខសម្រាប់ស្នើសុំសេវាដែលត្រូវប្រើប្រាស់ដោយសាធារណជន ឬ វិស័យឯកជន និង ផ្នែកខាងក្រោយដែលត្រូវប្រើប្រាស់ដោយមន្ត្រីសម្រាប់ទទួលពាក្យស្នើសុំ, ត្រួតពិនិត្យ និង អនុម័តលើពាក្យស្នើសុំ។

៩- ការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ត្រូវរៀបចំ និង បែងចែកទៅតាមការកំណត់មុខងារតម្រូវការ (functional requirement) និង មុខងារមិនតម្រូវការ (non-functional requirement)។

១០- មុខងារតម្រូវការជាបញ្ជីនៃមុខងារដែលក្រសួង ស្ថាប័ន តម្រូវឱ្យអ្នកផ្តល់សេវាអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ផ្តល់សេវាអេឡិចត្រូនិកត្រូវមាន ដែលមានជាអាទិ៍៖

- កត់ត្រាកម្រងទិន្នន័យដែលត្រូវការក្នុងពាក្យស្នើសុំ
- ស្វ័យប្រវត្តិកម្ម និង/ឬ មានជំនួយពីបញ្ញាសិប្បនិម្មិត (AI assisted) នៅពេលបំពេញពាក្យស្នើសុំ, ការទទួលពាក្យ, ការត្រួតពិនិត្យ និងការអនុម័ត
- ទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក
- រក្សាទុកពាក្យស្នើសុំដែលបានបំពេញ ប៉ុន្តែមិនទាន់សម្រេចចិត្តដាក់ស្នើសុំ
- មុខងារតាមដានស្ថានភាពនៃពាក្យស្នើសុំបន្ទាប់ពីបានដាក់ស្នើសុំ
- មុខងារដើម្បីទទួលមតិយោបល់ពីអ្នកស្នើសុំសេវា ឬសាធារណៈជន
- យន្តការត្រួតពិនិត្យ និងអនុម័តពាក្យស្នើសុំជាពហុកម្រិត និងអាចផ្លាស់ប្តូរបានតាមតម្រូវការ
- ផ្តល់អាជ្ញាបណ្ណ លិខិតអនុញ្ញាត ឬវិញ្ញាបនបត្រជាទម្រង់អេឡិចត្រូនិក និង អាចផ្ទៀងផ្ទាត់បានជាមួយថ្នាល verify.gov.kh
- ផ្តល់ទម្រង់របាយការណ៍ដែលអាចផលិតបានតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- ផ្តល់ស្ថិតិ ឬ មុខងារវិភាគពីការកត់ត្រាទិន្នន័យ និងការផ្តល់សេវាកន្លងមក ដូចជា ចំនួនសេវាដែលបានផ្តល់តាមប្រភេទ, តាមឆ្នាំ, កម្រៃសេវា, រយៈពេលនៃការផ្តល់សេវា។ល។
- មានមុខងារបង្ហាញពីប្រវត្តិនៃពាក្យស្នើសុំ ដោយរួមបញ្ចូលទាំងការដាក់ពាក្យស្នើសុំ, ការទទួលពាក្យស្នើសុំ, ការត្រួតពិនិត្យ និងការអនុម័តលើពាក្យស្នើសុំ។ ក្នុងកំឡុងពេលនៃការត្រួតពិនិត្យ,

ពាក្យស្នើសុំអាចត្រូវបានបញ្ជូនទៅកាន់មន្ត្រីជំនាញនានាដើម្បីពិនិត្យលក្ខណៈបច្ចេកទេស ឬ បញ្ជូនត្រឡប់ទៅកាន់អ្នកស្នើសុំសេវាដើម្បីកែតម្រូវព័ត៌មាន ឬ បំពេញព័ត៌មានដែលខ្វះខាត។ ក្នុងកំឡុងពេលត្រួតពិនិត្យនេះ, ប្រព័ន្ធត្រូវមានកំណត់ត្រាជាប្រវត្តិ ឬ ដំណាក់កាលវិវត្តន៍ស្ថានភាពនៃពាក្យស្នើសុំ ដែលអ្នកស្នើសុំមានសិទ្ធដឹងអំពីស្ថានភាពទាំងអស់នេះ

- កំណត់ពីសិទ្ធិអ្នកប្រើប្រាស់នៅក្នុងប្រព័ន្ធផ្នែកខាងក្រោយ។

១១- មុខងារមិនតម្រូវការ ជាមុខងារដែលក្រសួង ស្ថាប័នមិនបានគិតថាជាតម្រូវការរបស់ស្ថាប័នខ្លួននៅពេលផ្តល់សេវា ប៉ុន្តែមុខងារនេះជាការបំពេញបន្ថែម ដើម្បីឱ្យប្រព័ន្ធមានលក្ខណៈទំនើប, មានសុវត្ថិភាព, អាចទទួលប្រតិបត្តិការច្រើនក្នុងពេលតែមួយ, អាចធ្វើសន្ទានកម្មជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដទៃទៀត។ល។ មុខងារមិនតម្រូវការ ផ្តល់សារៈសំខាន់ក្នុងការដំណើរការប្រព័ន្ធជាផ្នែកមួយនៃប្រព័ន្ធអេកូឡូស៊ីនៃការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច ដែលធ្វើអន្តរ-ប្រតិបត្តិការជាមួយនឹងប្រព័ន្ធរបស់ស្ថាប័នដទៃទៀត និងធានានូវការប្រើប្រាស់ ព្រមទាំងថែទាំប្រព័ន្ធបានយូរអង្វែង។ មុខងារមិនតម្រូវការ មានដូចជា៖

- គួររៀបចំនិម្មាបនកម្មនៃប្រព័ន្ធជា Microservices
- រៀបចំ API ទទួលទិន្នន័យ, ចែករំលែកទិន្នន័យរបស់ប្រធានទិន្នន័យក្នុងការផ្ទៀងផ្ទាត់ និងការទាញទិន្នន័យមកដាក់នៅលើប្រព័ន្ធ ដើម្បីសម្រួលដល់ការបញ្ចូលទិន្នន័យនៃពាក្យស្នើសុំ
- រៀបចំ API ចែករំលែកទិន្នន័យពីស្ថានភាពរបស់ពាក្យស្នើសុំ, របាយការណ៍, និង ស្ថិតិ
- រៀបចំយន្តការសុវត្ថិភាពក្នុងការអភិវឌ្ឍប្រព័ន្ធដែលមានដូចជាប្រើប្រាស់ Hash Function សម្រាប់បំប្លែងទិន្នន័យឯកទិស, Encryption សម្រាប់បំប្លែងទិន្នន័យទ្វេទិស, និង ប្រើប្រាស់យន្តការ Authentication លើការបញ្ជូនទិន្នន័យ
- ពិនិត្យឡើងវិញនូវការប្រើប្រាស់ម៉ូឌុលនៃសុសវែរដែលអភិវឌ្ឍដោយភាគីទី ៣ ដើម្បីចៀសវាងបញ្ហាប្រឈមនានា ដូចជាសុវត្ថិភាព, សុក្រិតភាព និងភាពដែលអាចជឿជាក់បាននៅពេលប្រតិបត្តិការ
- ក្នុងករណីត្រូវប្រើប្រាស់ម៉ូឌុលសុសវែរដែលអភិវឌ្ឍដោយភាគីទី ៣, ត្រូវជ្រើសយកតែម៉ូឌុលដែលផ្តល់អាទិភាពលើម៉ូឌុលសុសវែរដែលមានអ្នកប្រើប្រាស់ច្រើន, ជាកូដបើកចំហ និង មានឯកសារណែនាំគ្រប់គ្រាន់
- រៀបចំប្រព័ន្ធដែលអាចទទួលប្រតិបត្តិការយ៉ាងហោចណាស់ ១០០ ក្នុងមួយនាទី
- ចំពោះអាជ្ញាបណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ លិខិតរដ្ឋបាលផ្សេងៗ ដែលត្រូវបានអនុម័តដោយក្រសួង ស្ថាប័នត្រូវមាននិម្មិតសញ្ញា (logo) របស់ថ្នាល CamDX
- គួរប្រើប្រាស់ផលិតផលឌីជីថល (digital products) ដែលមានស្រាប់ ដើម្បីជាជំនួយដល់ការអភិវឌ្ឍប្រព័ន្ធ ដូចជា៖ Go.gov.kh, Qr.gov.kh, Form.gov.kh, Nomsa.gov.kh ជាដើម
- រៀបចំមុខងាររបាយការណ៍ Audit Trails ដើម្បីងាយស្រួលក្នុងការធ្វើ IT Audit។

## ៣.២- គោលការណ៍បច្ចេកទេសសម្រាប់ការអភិវឌ្ឍប្រព័ន្ធ

### ១២- ការរៀបចំផែនការ និង គ្រប់គ្រងគម្រោង

ក. **គោលការណ៍៖** រៀបចំឯកសារផែនការ និង ការគ្រប់គ្រងគម្រោងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬ កម្មវិធីឱ្យបានច្បាស់លាស់ និង ធានាដល់ការអនុវត្តឱ្យមានប្រសិទ្ធភាព។

ខ. **ស្តង់ដា៖**

- **វិធីសាស្រ្តអភិវឌ្ឍកម្មវិធី៖** ជ្រើសយកវិធីសាស្រ្តអភិវឌ្ឍកម្មវិធីណាដែលស័ក្តិសមបំផុតសម្រាប់គម្រោងជាក់លាក់នីមួយៗ។ វិធីសាស្រ្តនីមួយៗមានចំណុចខ្លាំង និង ចំណុចខ្សោយផ្សេងៗគ្នា ហើយត្រូវបានប្រើប្រាស់ទៅតាមតម្រូវការជាក់ស្តែងនៃគម្រោង។ វិធីសាស្រ្តទាំងនោះរួមមាន វិធីសាស្រ្ត Agile, វិធីសាស្រ្ត Scrum, វិធីសាស្រ្ត Waterfall ឬវិធីសាស្រ្ត Spiral ជាដើម។ល។
- **ឯកសារណែនាំ (documentation)៖** រៀបចំឯកសារណែនាំលម្អិតអំពីតម្រូវការ (requirements) តាមដំណាក់កាល រួមមាន ដំណាក់កាលរៀបចំ (design), អភិវឌ្ឍ (development) និង ធ្វើតេស្ត (testing)។ ការរៀបចំឯកសារណែនាំ អាចប្រើប្រាស់កម្មវិធីដូចជា Confluence, GitBook ជាដើម។
- **ការគ្រប់គ្រងកំណែ (version control)៖** ប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងកំណែប្រែដូចជា Git ជាដើម ដើម្បីតាមដានមើលនូវការកែប្រែកូដ ហើយអាចសហការគ្នាយ៉ាងមានប្រសិទ្ធភាព។ ថ្នាល ឬ ប្រព័ន្ធដែលពេញនិយមប្រើប្រាស់មានដូចជា GitHub, GitLab និង Bitbucket ជាដើម។

### ១៣- ការគ្រប់គ្រងគុណភាពនៃកូដ

ក. **គោលការណ៍៖** ធានាឱ្យបាននូវគុណភាពនៃកូដរបស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សំដៅដល់ការសរសេរកូដឱ្យមានលក្ខណៈស្តង់ដារួម, ងាយស្រួលយល់, ងាយស្រួលថែទាំ ព្រមទាំងមានប្រសិទ្ធភាព និង អាចប្រើប្រាស់ឡើងវិញបាន ហើយត្រូវតែគិតគូរដល់ការរក្សាសុវត្ថិភាព, ការពង្រីកវិសាលភាព, ការធ្វើតេស្ត និង ការរៀបចំឯកសារណែនាំត្រឹមត្រូវ (documentation)។

ខ. **ស្តង់ដា**

- **ស្តង់ដាកូដ៖** អនុវត្តតាមស្តង់ដាសរសេរកូដ ដែលបានបង្កើតឡើងសម្រាប់ភាសានីមួយៗ ដើម្បីធានាបាននូវភាពស៊ីចង្វាក់គ្នា, សាមញ្ញ ហើយអាចឱ្យគេងាយមើលយល់បាន។ ឧទាហរណ៍៖ ការណែនាំដោយ Google ក្នុងការអនុវត្តកូដភាសា Java, PEP ៨ សម្រាប់ភាសា Python, ការណែនាំដោយ Airbnb សម្រាប់ភាសា JavaScript ឬ TypeScript ជាដើម។ល។
- **ការត្រួតពិនិត្យកូដ៖** ការត្រួតពិនិត្យកូដដោយប្រើប្រាស់យន្តការ Pull Request នៅក្នុង GitHub ឬ GitLab ជាប្រចាំ អាចធានាបាននូវគុណភាពកូដប្រសើរ ហើយដើម្បីធានានូវការប្រកាន់ខ្ជាប់នូវការសរសេរកូដក្នុងលំនាំស្តង់ដាល្អ និង ការបែងចែកម៉ូឌុលដាច់ៗគ្នាជាដើម។ ក្នុងនោះ ការសរសេរកូដដោយមានដៃគូសហការ អាចនាំមកនូវការកែលម្អ ឬ ចែករំលែកចំណេះដឹងបានភ្លាមៗ រួមជាមួយនឹងការត្រួតពិនិត្យកូដស្វ័យប្រវត្តិដោយប្រើប្រាស់ SonarQube

ជាដើម។ អ្នកត្រួតពិនិត្យកូដត្រូវធ្វើតាមឧត្តមានុវត្តន៍ និងស្តង់ដានៃការសរសេរកូដ ដោយមានគោលបំណង និង បញ្ជីត្រួតពិនិត្យជាក់លាក់។

- **ការវិភាគកូដ៖** ប្រើប្រាស់នូវកម្មវិធីដើម្បីរកមើលនូវកំហុសឆ្គងនៅក្នុងកូដ និង ត្រួតពិនិត្យនូវគុណភាពកូដដើម្បីធានានូវស្តង់ដាកូដដែលល្អ។

## ១៤- ការរក្សាសុវត្ថិភាព

ក. **គោលការណ៍៖** ធានាឱ្យបាននូវសុវត្ថិភាពសម្រាប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬ ការគំរាមកំហែងផ្សេងៗ។

ខ. **ស្តង់ដា៖**

❖ ធ្វើតាមឧត្តមានុវត្តន៍នៃ Open Web Application Security Project (OWASP) ចំពោះសុវត្ថិភាពនៃកម្មវិធីវេប៖

- **ការគ្រប់គ្រងសិទ្ធិប្រើប្រាស់៖** ត្រូវកំណត់សិទ្ធិលើប្រព័ន្ធឱ្យបានច្បាស់លាស់ ដើម្បីការពារពីការចូលទៅមើល ឬ ប្រើប្រាស់ ពីអ្នកប្រើប្រាស់ និង ធានាថាការចូលប្រើប្រាស់ប្រព័ន្ធ ឬ មើលទិន្នន័យផ្សេងៗ មានការគ្រប់គ្រងបានត្រឹមត្រូវ។
- **ការប្រើប្រាស់កូដវិទ្យា៖** ត្រូវធានាថា រាល់ការធ្វើប្រតិបត្តិការទិន្នន័យ ផ្លាស់ប្តូរទិន្នន័យ ឬការរក្សាទុកទិន្នន័យដែលរសើប ត្រូវតែមានការធ្វើកូដនីយកម្មលើទិន្នន័យជាចាំបាច់ ដោយប្រើ-ប្រាស់យន្តការកូដវិទ្យាដែលទំនើប និង ខ្លាំង។
- **ការការពារទិន្នន័យបញ្ចូលដោយអ្នកប្រើប្រាស់៖** ធានាថារាល់ទិន្នន័យដែលបញ្ចូលដោយអ្នក-ប្រើប្រាស់ត្រូវតែធ្វើការសម្អាត និង ត្រួតពិនិត្យជាមុន ចៀសវាងការបញ្ចូលទិន្នន័យដែលអាចប៉ះពាល់ដល់ប្រព័ន្ធ និង អាចឱ្យប្រព័ន្ធរងការវាយប្រហារបាន។
- **ការកំណត់មុខងារសុវត្ថិភាពមិនត្រឹមត្រូវ៖** រាល់ការប្រើប្រាស់មុខងារសុវត្ថិភាពទាំងអស់ ត្រូវប្រាកដថាបានអនុវត្តត្រឹមត្រូវលើការកំណត់មុខងារផ្សេងៗ។
- **សមាសធាតុដែលមានចន្លោះប្រហោង (vulnerable components) និង ហួសសុពលភាព៖** ត្រូវធានាថា រាល់ការប្រើប្រាស់សមាសធាតុផ្សេងៗ (ដូចជា dependencies ឬ library) ឬឧបករណ៍កម្មវិធីនានា ពីខាងក្រៅ ត្រូវតែធ្វើបច្ចុប្បន្នភាពឱ្យបានទៀងទាត់ ចៀសវាងប្រើប្រាស់សមាសធាតុណាមួយដែលមានចន្លោះប្រហោង ឬហួសសុពលភាព។
- **ការកំណត់អត្តសញ្ញាណ និង យថាភូតកម្ម៖** ត្រូវកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់ឱ្យបានច្បាស់លាស់ តាមរយៈការធ្វើយថាភូតកម្ម នៅពេលមានការចូលទៅប្រើប្រាស់ទិន្នន័យ ឬ ចូលទៅធ្វើសកម្មភាពផ្សេងៗនៅលើប្រព័ន្ធ។
- **សុចរិតភាពនៃកម្មវិធី និង ទិន្នន័យ៖** នៅពេលប្រើប្រាស់កម្មវិធី ឬ ឧបករណ៍ផ្សេងៗពីខាងក្រៅ ដូចជា dependencies ឬ library ជាដើម ត្រូវធានាឱ្យបាននូវសុចរិតភាព និង ភាពត្រឹមត្រូវនៃសមាសធាតុទាំងនោះ ទាក់ទងនឹងសុវត្ថិភាព។

- **ការកត់ត្រា និង ត្រួតពិនិត្យសកម្មភាពផ្សេងៗ៖** ក្នុងការអភិវឌ្ឍប្រព័ន្ធ ត្រូវតែកត់ត្រាទុកនូវសកម្មភាពផ្សេងៗដែលទាក់ទងនឹងសុវត្ថិភាព របស់អ្នកប្រើប្រាស់ និង របស់ប្រព័ន្ធ ហើយរក្សាទុកនូវកំណត់ត្រានេះឱ្យបានត្រឹមត្រូវ ដើម្បីងាយស្រួលប្រើប្រាស់នៅពេលចាំបាច់។

❖ ធ្វើតាមឧត្តមានុវត្តន៍នៃ OWASP ចំពោះបញ្ជីត្រួតពិនិត្យសុវត្ថិភាពនៃកម្មវិធីទូរសព្ទ៖

- **កន្លែងផ្ទុកទិន្នន័យ៖** ត្រូវជ្រើសយក ឬ ប្រើប្រាស់ប្រភេទនៃកន្លែងផ្ទុកទិន្នន័យឱ្យបានត្រឹមត្រូវនៅលើទូរសព្ទ ជាពិសេសចំពោះទិន្នន័យរសើប។
- **កូដវិទ្យា៖** ត្រូវប្រើប្រាស់នូវយន្តការការពារទិន្នន័យនៅលើទូរសព្ទ ដោយធ្វើកូដនីយកម្មលើទិន្នន័យដែលសំខាន់ និង ត្រូវការពារទិន្នន័យប្រភេទជាពាក្យសម្ងាត់ ឬ កូដសម្ងាត់ឱ្យបានត្រឹមត្រូវ។
- **យថាភូតកម្ម៖** ត្រូវធានាថាការរក្សាទុកនូវព័ត៌មានយថាភូតកម្មរបស់អ្នកប្រើប្រាស់នៅលើទូរសព្ទមានសុវត្ថិភាព ដោយអាចប្រើប្រាស់កូដវិទ្យា ហើយរួមគ្នាជាមួយនឹងមុខងារយថាភូតកម្មជាមួយជីវមាត្រជាដើម។
- **បណ្ដាញតភ្ជាប់៖** ការផ្លាស់ប្ដូរទិន្នន័យរវាងទូរសព្ទ ទៅកាន់អ៊ីនធឺណិតត្រូវធ្វើកូដនីយកម្មជាមុនសិន ឬ យ៉ាងហោចណាស់ប្រើប្រាស់នូវ TLS/SSL ជាដើម។
- **ប្រភេទឧបករណ៍ទូរសព្ទ៖** ត្រូវពិនិត្យមើលលទ្ធភាពដែលទិន្នន័យអាចលេចធ្លាយនៅពេលអភិវឌ្ឍ, នៅតាមការប្រើប្រាស់មុខងារផ្សេងៗនៅលើឧបករណ៍ទូរសព្ទ (mobile device features) ឬ តាមការអនុញ្ញាតផ្សេងទៀតលើមុខងារក្នុងទូរសព្ទ ដូចជាការអនុញ្ញាតបើកទិន្នន័យទីតាំង (location data), ឧបករណ៍ស្រូបសម្លេង (microphone) ឬ កាមេរ៉ាជាដើម។
- **កូដ៖** ត្រូវពិនិត្យមើលគុណភាពនៃកូដ និង ធានាថាមិនមានកំហុសឆ្គងផ្នែកសុវត្ថិភាព ដូចជាការប្រើប្រាស់កន្លែងផ្ទុកទិន្នន័យ ការប្រើប្រាស់ dependencies ឬ library ពីខាងក្រៅជាដើម។
- **ភាពធន់នៃកម្មវិធី៖** ត្រូវធានាថាកម្មវិធីទូរសព្ទដែលបានអភិវឌ្ឍមានភាពធន់នឹងការប្រើប្រាស់ជាពិសេសធន់នឹងការវាយប្រហារផ្សេងៗ ដូចជាការធ្វើ reverse engineer, ការលួចយកទិន្នន័យនៅក្នុងកម្មវិធី, ការធ្វើ Jailbreak ឬ Root ជាដើម។
- **ឯកជនភាព៖** កម្មវិធីទូរសព្ទត្រូវតែផ្ដល់លទ្ធភាពជូនអ្នកប្រើប្រាស់ក្នុងការគ្រប់គ្រងទិន្នន័យរបស់ខ្លួន និង ត្រូវប្រើប្រាស់ទិន្នន័យអ្នកប្រើប្រាស់ឱ្យកាន់តែតិចតាមតែអាចធ្វើបាន ប្រកបដោយតម្លាភាព។

## ១៥. ការធ្វើតេស្ត

ក. **គោលការណ៍៖** បង្កើនប្រសិទ្ធភាពនៃការធ្វើតេស្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬកម្មវិធី ដើម្បីផ្ដល់នូវបទពិសោធដល់អ្នកប្រើប្រាស់ដោយរលូន និង ធានាឱ្យបាននូវស្ថិរភាពនៃប្រព័ន្ធបច្ចេកវិទ្យា-ព័ត៌មាន។

